ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 17 ខែ 06 ឆ្នាំ 2003

# មាតិកា

## I – ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-៥-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៩ បញ្ឈប់ភារកិច្ចរបស់
ឯកឧត្តម **ឃុន ជិនកេន** ពីអគ្គលេខាធិការរង រាជរដ្ឋាភិបាល ១៤០១

២៩-៥-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៨០ ស្តីពីការបង្កើត
រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ១៤០២

២៩-៥-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៨១ តែងតាំង ឯកឧត្តម
**លន់ សុជាតិ** ជាអគ្គលេខាធិការរង នៃក្រុមសង្កេតការណ៍
សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី ១៤០៧

២៩-៥-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៨២ លើកលែងទោសឱ្យ
ទណ្ឌិត ចំនួន ០២នាក់ ១៤០៨

២៩-៥-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៨៦ តែងតាំងឯកឧត្តម
**សំ សោភាន់** ជាប្រធានវិជ្ជាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម
នៃរាជបណ្ឌិតសភាកម្ពុជា ១៤០៩

៣១-៥-២០០១ -នស/រកត/០៥០១/១៨៨ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់
គ្រួសារ ១-លោក **ភុង លុកសេន** ២-អ្នកស្រី **ស៊ូ ឈីអេង** ១៤១០

## II – រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៤-៥-២០០១ -អនុក្រឹត្យ លេខ ៤៣ អនក្រ។បក ស្តីពីការបង្កើត និងការ
ប្រព្រឹត្តិទៅនៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១៤១១

២៩-៥-២០០១ -អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពីការកែសំរួលអត្រាពន្ធនិងអាករ
លើទំនិញមួយចំនួន ១៤១៤

៣០-៥-២០០១ -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្តីពីការបង្កើតក្រុមការងារ ជាន់ខ្ពស់ ១៤២១

| | | |
|---|---|---|
| ៣០-៥-២០០១ | -អនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៤២២ |
| ២៤-៥-២០០១ | -អនុក្រឹត្យលេខ ២២៩ អនក្រ.តតស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២៤ |
| ២៥-៥-២០០១ | -អនុក្រឹត្យលេខ ២៣០អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២៥ |
| ២៥-៥-២០០១ | -អនុក្រឹត្យលេខ ២៣១អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២៧ |
| ២៥-៥-២០០១ | -អនុក្រឹត្យលេខ ២៣២អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៤២៨ |
| ២៥-៥-២០០១ | -អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៤២៩ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣១ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣២ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៣៦អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣៣ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៣៧អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣៤ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៣៨អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣៦ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៣៩អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣៧ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៤០អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៣៨ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៤១អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ១៤៣៩ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៤២អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៤១ |
| ២៩-៥-២០០១ | -អនុក្រឹត្យលេខ ២៤៣អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៤២ |
| ៣១-៥-២០០១ | -អនុក្រឹត្យលេខ ២៤៤អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៤៤៤ |
| ៣១-៥-២០០១ | -អនុក្រឹត្យលេខ ២៤៥អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៤៤៥ |


## ២. សេចក្តីប្រកាស


| | | |
|---|---|---|
| ២៨-៥-២០០១ | -សេចក្តីប្រកាសលេខ០២ប្រក ស្តីអំពីកាលបរិច្ឆេទនៃការចាប់ផ្តើម ពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោត ជ្រើសរើស ក្រុមប្រឹក្សា ឃុំ សង្កាត់ | ១៤៤៦ |

# III – ការងារបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី

## ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

### ប្រកាស

២៩-៥-២០០១ -ប្រកាសលេខ ០១២/០១ ទរពអ-ប្រក ស្តីពីការកំណត់តួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋ- សភា ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត-ក្រុង ១៤៤៧

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

### ប្រកាស

២៩-៥-២០០១ -ប្រកាសលេខ៦៥ផក.ប្រកស្តីពីការប្រើប្រាស់កំរងទិន្នន័យមូលដ្ឋាន ឃុំ- សង្កាត់ ១៤៥៣

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

### សេចក្តីសំរេច

២៤-៥-២០០១ -សេចក្តីសំរេចលេខ ១៥២ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រិស្តឈ្មោះ (**ប្រេទ្រីនបាជ័យ**) ស្ថិតនៅភូមិបាជ័យ ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ១៤៧១

២៤-៥-២០០១ -សេចក្តីសំរេចលេខ ១៥៣ កធស.សរអនុញ្ញាតអោយបើក សាខាស្នាក់ការថ្វាយបង្គំនៃសាសនាគ្រិស្តឈ្មោះ(**បាប់ទីស្ទគ្រួសារព្រះ**) ស្ថិតនៅភូមិទូលគោក សង្កាត់ទូលសង្កែ ស្រុកឫស្សីកែវ រាជធានីភ្នំពេញ ១៤៧២

២៤-៥-២០០១ -សេចក្តីសំរេចលេខ ១៥៤ កធស.សរ អនុញ្ញាតអោយបើក សាខាស្នាក់ការថ្វាយបង្គំសាសនាព្រះគ្រិស្តឈ្មោះ(**ក្រុមជំនុំគ្រិស្តបរិស័ទបាប់ទីស្ទភ្នំពេញទី១**) ស្ថិតនៅក្រុមទី២៤ សង្កាត់ផ្សារដើម ថ្កូវ ខ័ណ្ឌចំការមនរាជធានីភ្នំពេញ ១៤៧៣

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានបញ្ឈប់ភារកិច្ចរបស់ឯកឧត្តម **ឃុន ជិនកេន** ពីអគ្គលេខាធិការរងរាជរដ្ឋាភិបាល ឱ្យមក បំរើការងារ ជាមន្ត្រីរាជការក្រោមឱវាទរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២.-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨០

## ស្តីពី

## ការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ

---

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនិ៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៨/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើត រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ដែលស្ថិតក្នុងឃុំផ្សារដែក និង ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះ មានគោលបំណង

-អភិរក្សកេរដំណែលបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ

-អភិវឌ្ឍតំបន់ទេសចរណ៍

-អភិរក្សបរិស្ថាន វប្បធម៌ ធម្មជាតិ ។

រមណីយដ្ឋាននេះ ត្រូវបានប្រកាសជាតំបន់បំរើឱ្យផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ២

## ការកំណត់តំបន់

**មាត្រា ៣.-**

រមណីយដ្ឋានភ្នំព្រះរាជទ្រព្យនេះមានទំហំ ៥០៨ហិកតា ត្រូវបានបែងចែកជាបីតំបន់ផ្សេងគ្នា ដូចតទៅ :

ក- តំបន់ទី១ គឺជា : តំបន់អភិរក្សបេតិកភណ្ឌប្រវត្តិសាស្ត្រ ហៅថា តំបន់ស្នូល ហើយស្ថិតនៅក្នុងរង្វង់អ័ក្សផ្លូវជុំវិញជើងភ្នំ ដែលមានទំហំ ៧៩ ហិកតា។

ខ- តំបន់ទី២ គឺជា : តំបន់អភិវឌ្ឍសេដ្ឋកិច្ចទេសចរណ៍ហៅថា តំបន់ទ្រនាប់ ហើយស្ថិតក្នុងចន្លោះព្រំប្រទល់ អ័ក្សផ្លូវជុំវិញជើងភ្នំ និងខ្សែបន្ទាត់ព្រំប្រទល់ a,b.c,d...,m ដែលមានទំហំ ២១៧ ហិកតា។

គ- តំបន់ទី៣ គឺជា : តំបន់អភិរក្ស និងថែរក្សាការពារបរិស្ថានធម្មជាតិ ហៅថា តំបន់រណប ហើយស្ថិតនៅចន្លោះខ្សែបន្ទាត់ព្រំប្រទល់ a,b.c,d...,m និងខ្សែបន្ទាត់ព្រំប្រទល់ A,B,C,D...,L ដែលមានទំហំ ២១២ ហិកតា។

និយាមការនៃចំណុច ខ្សែបន្ទាត់ព្រំប្រទល់ a,b,c,d...,e,f,g,h,i,j,k,l,m និង ខ្សែបន្ទាត់ព្រំប្រទល់ A,B,C,D,E,F,G,H,I,J,K,L មាននៅក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២។

**មាត្រា ៤.-**

បែបបទ និងនីតិវិធីនៃការគ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

## ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៨០
## ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១
## តារាងសម្រង់និយាមការនៃចំណុចព្រំប្រទល់ផ្នែកខាងក្រៅ
## របស់តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចទេសចរណ៍ (តំបន់២)

| ល.រ | X (E) | Y (N) |
|---|---|---|
| a | 474705.03 | 1304886.90 |
| b | 475180.99 | 1304309.39 |
| c | 475567.11 | 1394330.35 |
| d | 476211.78 | 1303127.94 |
| e | 476194.07 | 1302994.03 |
| f | 475968.68 | 1302920.21 |
| g | 476128.19 | 1302448.37 |
| h | 475556.83 | 1302381.38 |
| i | 475009.66 | 1302539.27 |
| j | 474742.69 | 1303305.68 |
| k | 474033.76 | 1304046.80 |
| l | 474033.69 | 1304255.43 |
| m | 474602.00 | 1304881.45 |

## តារាងសម្រង់និយាមការនៃចំណុចព្រំប្រទល់ផ្នែកខាងក្រៅ
## របស់តំបន់អភិរក្ស និង ថែរក្សាបរិស្ថានធម្មជាតិ (តំបន់៣)

| ល.រ | X (E) | Y (N) |
|---|---|---|
| A | 474435.05 | 1305460.34 |
| B | 474850.04 | 1305458.15 |
| C | 474847.31 | 1304940.15 |
| D | 475640.60 | 1304613.97 |
| E | 476393.97 | 1303542.98 |
| F | 476397.89 | 1302768.95 |
| G | 476183.87 | 1302766.08 |
| H | 476174.48 | 1302314.12 |
| I | 474929.42 | 1302304.69 |
| J | 473942.00 | 1303744.91 |
| K | 473948.32 | 1304944.89 |
| L | 474432.32 | 1304942.34 |

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ ន.ស/រកត/០៥០១/១៨០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០១



# ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានតែងតាំង ឯកឧត្តម **លន់ សុជាតិ** ជាអគ្គលេខាធិការរង នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យ លេខ ២៨ក្រ ចុះថ្ងៃទី ២០-៦-៨៨
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានលើកលែងទោសឱ្យទណ្ឌិត ចំនួន ០២នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ។

១- ទណ្ឌិតឈ្មោះ **ហ៊ាន ម៉ៅខ្លឹង** ដែលត្រូវបានផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់តុលាការយោធា ។

២- ទណ្ឌិតឈ្មោះ **កែវ សុវណ្ណរ័ត្ន** ដែលត្រូវបានផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់តុលាការយោធា ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ តុលាការយោធា ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះឱ្យបានស្ថាពរ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ មានអនុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

* * *

# ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតណ៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

  បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានតែងតាំង ឯកឧត្តម **សំ សោភាន់** ជាប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយករង**

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

* * *

**ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨៨**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១.-** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់គ្រួសារលោក **គុង លុកសេន** ដូចរាយនាមខាងក្រោម :-

១- លោក **គួង លុកសេន** (KONG LOOK SEN) ហៅ KWONG LOCK KING សញ្ជាតិសឹង្ហបូរី កើតថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៣៦ នៅ PERAK ប្រទេសម៉ាឡេស៊ី.

២- អ្នកស្រី **ស៊ូ លីអេង** (SOO LEE ENG) (ភរិយា) សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៤០ នៅ PERAK ប្រទេសម៉ាឡេស៊ី ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

===

# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ៤៣ អនក្រ.បក

## ស្តីពី

## ការបង្កើត និង ការប្រព្រឹត្តិទៅនៃ

## លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រុម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រុម

យោងតាមសំណើរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម លេខ ៧០ ឧក្រច ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០១

**សំរេច**

**មាត្រា ១.-** ត្រូវបានបង្កើតលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អោយទទួលបន្ទុករៀបចំចាត់ចែងការងារធ្វើកំណត់ហេតុ ធ្វើរបាយការណ៍ ទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និងជាអ្នកសំរបសំរួលជាមួយក្រសួងយុត្តិធម៌ ។

**មាត្រា ២.-** លេខាធិការដ្ឋាន មានភារកិច្ចធ្វើជាសេនាធិការអោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការធ្វើអោយដំណើរការនៃប្រព័ន្ធតុលាការបានល្អប្រសើរ និងឯកភាពគ្នា ។

**មាត្រា ៣.-** លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដឹកនាំដោយលេខាធិការម្នាក់ និងលេខាធិការរង តាមការចាំបាច់ ។ លេខាធិការត្រូវជ្រើសតាំងសំរាប់អាណត្តិ ០៥ឆ្នាំ ក្នុងចំណោមសមាជិកជ្រើសតាំង ០៣នាក់ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំលើកទី១ របស់ខ្លួន ។ លេខាធិការរង ត្រូវជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រមដែលមានអតីតភាព យ៉ាងតិច ០៥ឆ្នាំ ។

លេខាធិការ ក្នុងការដឹកនាំបញ្ហាការងាររដ្ឋបាល នៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសិទ្ធិចុះហត្ថលេខាលើលិខិត ឬ សេចក្តីសំរេចរដ្ឋបាល និងការងារផ្សេងៗទៀត ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រគល់អោយនាសម័យប្រជុំនីមួយៗ ។ លេខាធិការរងមានភារកិច្ចជួយលេខាធិការក្នុងការបំពេញការងារខាងលើ និងតាមការប្រគល់សិទ្ធិរបស់លេខាធិការ ។

**មាត្រា ៤.-** លេខាធិការ និងលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំរបស់សម័យប្រជុំ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ។ លេខាធិការមានឋានៈ និងបុព្វសិទ្ធិស្មើនឹង រដ្ឋលេខាធិការ ហើយលេខាធិការរង មានឋានៈ និងបុព្វសិទ្ធិស្មើនឹង អនុរដ្ឋលេខាធិការ ។

**មាត្រា ៥.-** លេខាធិការដ្ឋានត្រូវបែងចែកជា នាយកដ្ឋានជំនួយការកិច្ចការតុលាការ និងនាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ច ។ នាយកដ្ឋានទាំងពីរត្រូវបែងចែកជាការិយាល័យតាមការសំរេច នៃសម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមសំណើរបស់លេខាធិការ ។

មាត្រា ៦.- នាយកដ្ឋានជំនួយការកិច្ចការតុលាការ ត្រូវដឹកនាំដោយប្រធានម្នាក់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យក្នុងចំណោមចៅក្រមដែលមានសមត្ថភាព និងបទពិសោធណ៍តាមសំណើរបស់សម័យប្រជុំនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច ត្រូវតែងតាំងដោយព្រះរាជក្រឹត្យក្នុងចំណោមមន្ត្រី ដែលមានបទពិសោធន៍ផ្នែករដ្ឋបាល-ហិរញ្ញកិច្ច តាមសំណើរបស់សម័យប្រជុំនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

នាយកដ្ឋាននីមួយៗ មានអនុប្រធាន តាមការចាំបាច់ ដែលត្រូវតែងតាំងដោយសេចក្តីសំរេចរបស់សម័យប្រជុំ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។

មាត្រា ៧.- ថវិកាសំរាប់ដំណើរការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបែងចែកពីថវិការបស់ក្រសួងយុត្តិធម៌ ដោយវិលែកពីគំរោងចំណាយចែកជាផ្នែក ឬ ប្រការ តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាអាណាប័កដើមខ្សែ។ ចំណាយទាំងអស់ត្រូវធ្វើអាណត្តិបើកប្រាក់ដោយលេខាធិការ. គណនេយ្យករម្នាក់ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អោយទទួលបន្ទុកជាភ្នាក់ងារបើកផ្តល់។

មាត្រា ៨.- មន្ត្រីទាំងអស់នៃលេខាធិការដ្ឋាន ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជីក្នុងក្របខ័ណ្ឌ ឬ អាចជ្រើសរើសថ្មី។ បរិមាណនៃមន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ត្រូវកំណត់ក្នុងចំនួនអប្បរមាដែលអាចធ្វើទៅបាន។

មាត្រា ៩.- មន្ត្រីរាជការ នៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម មានប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ស្មើនឹងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

មាត្រា ១០.- កំណត់ហេតុទាំងអស់ និងឯកសារផ្សេងៗទៀត រួមទាំងឯកសាររបស់ក្រុមប្រឹក្សាវិន័យផងត្រូវរក្សាទុកក្នុងលេខាធិការដ្ឋាន។ លេខាធិការធានាការបែងចែកឯកសារសម្ងាត់ទាំងឡាយ។

សមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម មានសិទ្ធិពិនិត្យឯកសារទាំងឡាយដែលរក្សាទុកនៅលេខាធិការដ្ឋាន។

## អន្តរបញ្ញត្តិ

មាត្រា ១១.- ក្នុងពេលដែលឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមមិនទាន់អាចរៀបចំថវិកាដោយឡែករបស់ខ្លួនបាន ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរ៉ាប់រង ថវិកាចាំបាច់សំរាប់ដំណើរការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។

**មាត្រា ១២.-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៤៤ អនក្រ.បក

## ស្តីពី

## ការកែសំរួលអត្រាពន្ធ និងអាករ លើទំនិញមួយចំនួន

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៩៦ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០១ន ។ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤

ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសឱ្យដោយក្រឹត្យលេខ ៥៧ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញច្បាប់សារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០

យោងស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ នាទីស្តីការគណៈរដ្ឋមន្ត្រី និងតំរូវការចាំបាច់ចំពោះមុខ

**សំរេច**

**មាត្រា ១.-** ត្រូវបានកែប្រែ និងកំណត់អត្រាអាករពិសេសលើបណ្តាមុខទំនិញមួយចំនួន ដែលមានចែងក្នុងតារាងពន្ធគយកម្ពុជាជាធរមានដូចខាងក្រោម :

**ក.- O ភាគរយ** សំរាប់ផលិតផលតេលសិលា ដែលមានទីតាំងរងលេខ ២៧១០.០០.៨៤ ។

**ខ.- ៤,៣៥ ភាគរយ :** សំរាប់ផលិតផលតេលសិលាដែលមានទីតាំងរងលេខ : ២៧១០.០០.៧១ ២៧១០.០០.៧២ និង ២៧១០.០០.៧៥

**គ.- ៥ ភាគរយ** : សំរាប់ទោចក្រយានយន្ត ដែលមានស៊ីឡាំងដ្រេមិនលើសពី ១២៥CC បំណែកនិងគ្រឿងបន្ទាស់ទោចក្រយានយន្ត ដែលមានទីតាំងរងលេខ : ៨៧១១.១០.០០ ៨៧១.២០.០០ ៨៧១១.៩០.១០ ៨៧១៤.១១.១០ ៨៧១៤.១៩.១០ ផលិតផលតេលសិលា ដែលមានទីតាំងរងលេខ ២៧១០.០០.៣៤ ២៧១០.០០.៣៦ ២៧១០.០០.៣៧ ២៧១០.០០.៥០ ២៧១០.០០.៦០ ២៧១០.០០.៨១ ២៧១០.០០.៨២ ២៧១០.០០.៨៧ និង ២៧១០.០០.៨៥ ។

**ឃ.១០ អាករយ** : សំរាប់ភេសជ្ជៈ បារី និងមុខទំនិញផ្សេងទៀត ដែលមានទីតាំងរងលេខ :

២២០២.១០.២០ ២២០២.១០.៩០ ២២០២.៩០.០០ ២២០៣.០០.១០
២២០៣.០០.៩០ ២២០៦.០០.១០ ២២០៦.០០.២០ ២២០៦.០០.៣០
២២០៦.០០.៤០ ២២០៦.០០៥០ ២២០៦.០០.៦០ ២២០៦.០០៧០
២២០៦.០០.៩០ ២២០៨.៩០.១០ ២២០៨.៩០.២០ ២២០៨.៩០.៣០
២២០៨.៩០.៤០ ២២០៨.៩០.៥០ ២២០៨.៩០.៦០ ២២០៨.៩០.៧០
២២០៨.៩០.៨០ ២២០៨.៩០.៩០ ២៤០២.២០.១០ ២៤០២.២០.៩០
៨៧០២.១០.១០ ៨៧០២.១០.២០ ៨៧០២.១០.៩០ ៨៧០២.៩០.០០
៨៧០៤.១០.០០ ៨៧០៤.២១.០០ ៨៧០៤.២២.០០ ៨៧០៤.២៣.០០
៨៧០៤.៣១.០០ ៨៧០៤.៣២.០០ និង ៨៧០៤.៩០.០០

ដែលជាប់អាករពិសេសតាមអត្រា ១០% ស្រាប់ហើយដែលមិនត្រូវបានកែប្រែដូចមានចែងក្នុងមាត្រានេះ ។

២២០៦.០០.១០ ២២០៦.០០.២០ ២២០៦.០០.៣០ ២២០៦.០០.៤០
២២០៦.០០.៥០ ២២០៦.០០.៦០ ២២០៦.០០.៧០ ២២០.៦០០.៩០
២២០៨.៩០.១០ ២២០៨.៩០.២០ ២២០៨.៩០.៣០ ២២០៨.៩០.៤០
២២០៨.៩០.៥០ ២២០៨.៩០.៦០ ២២០៨.៩០.៧០ ២០៨.៩០.៨០
២២០៨.៩០.៩០ ២៤០២.២០.១០ ២៤០២.២០.៩០ ៨៧០២.១០.១០
៨៧០២.១០.២០ ៨៧០២.១០.៩០ ៨៧០២.៩០.០០ ៨៧០៤.១០.០០
៨៧០៤.២១.០០ ៨៧០៤.២២.០០ ៨៧០៤.២៣.០០ ៨៧០៤.៣១.០០
៨៧០៤.៣២.០០ និង ៨៧០៤.៩០.០០

ដែលជាប់អាករពិសេសតាមអត្រា ១០% ស្រាប់ហើយ ដែលមិនត្រូវបានកែប្រែដូចមានចែងក្នុងមាត្រានេះ ។

**ខ.១៥ អាករយ** : សំរាប់កង់រថយន្តទេសចរណ៍ ដែលមានទីតាំងរងលេខ ៤០១១.១០.០០

រថយន្តមានស៊ីឡាំងជ្រៃមិនលើសពី ១០០០CC និងគ្រឿងបន្លាស់ ដែលមានទីតាំងរងលេខ :

៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២

៨៧១៤.១១.២០ ៨៧១៤.១៩.២០ ទំនិញដែលមានទីតាំងរងលេខ ៣៣០៣.០០.០០

និងទំនិញដែលមានទីតាំងរងលេខ ៩៥.០៥ និង ៩៥.០៨។

ច. **២៥ ភាគរយ** : សំរាប់បារី និងគ្រឿងបន្លាស់រថយន្ត ដែលមានទិតាំងរងលេខ :

២៤០២.១០.០០ ២៤០២.៩០.១០ ២៤០២.៩០.២០ ២៧១០.០០.៨៣ ៨៧០៦.០០.១០

៨៧០៦.០០.២១ ៨៧០៦.០០.២២ ៨៧០៦.០០.២៣ ៨៧០៦.០០.៩០ ៨៧០៧.១០.១០

៨៧០៧.១០.២០ ៨៧០៧.១០.៣០ ៨៧០៧.៩០.០០ ៨៧០៨.១០.១២ ៨៧០៨.១០.១៣

៨៧០៨.១០.១៤ ៨៧០៨.១០.១៥ ៨៧០៨.១០.៩២ ៨៧០៨.១០.៩៣ ៨៧០៨.១០.៩៤

៨៧០៨.១០.៩៥ ៨៧០៨.២១.២០ ៨៧០៨.២១.៣០ ៨៧០៨.២១.៤០ ៨៧០៨.២១.៥០

៨៧០៨.២៩.១២ ៨៧០៨.២៩.១៣ ៨៧០៨.២៩.១៤ ៨៧០៨.២៩.១៥ ៨៧០៨.២៩.៩២

៨៧០៨.២៩.៩៣ ៨៧០៨.២៩.៩៤ ៨៧០៨.២៩.៩៥ ៨៧០៨.៣១.២០ ៨៧០៨.៣១.៣០

៨៧០៨.២៩.៩៣ ៨៧០៨.២៩.៩៤ ៨៧០៨.២៩.៩៥ ៨៧០៨.៣១.២០ ៨៧០៨.៣១.៣០

៨៧០៨.៣១.៤០០ ៨៧០៨.៣១.៥០ ៨៧០៨..៣៩.២០ ៨៧០៨..៣៩.៣១ ៨៧០៨..៣៩.៤០

៨៧០៨.៣៩.៥០ ៨៧០៨.៤០.១២ ៨៧០៨.៤០.១៣ ៨៧០៨.៤០.១៤ ៨៧០៨.៤០.១៥

៨៧០៨.៤០.២២ ៨៧០៨.៤០.២៣ ៨៧០៨.៤០.២៤ ៨៧០៨.៤០២៥ ៨៧០៨.៥០.១២

៨៧០៨.៥០.១៣ ៨៧០៨.៥០.១៤ ៨៧០៨.៥០.១៥ ៨៧០៨.៥០.២២ ៨៧០៨.៥០.២៣

៨៧០៨.៥០.២៤ ៨៧០៨.៥០.២៥ ៨៧០៨.៦០.១២ ៨៧០៨.៦០.១៣ ៨៧០៨.៦០.១៤

៨៧០៨.៦០.១៥ ៨៧០៨.៦០.២២ ៨៧០៨.៦០.២៣ ៨៧០៨.៦០.២៤ ៨៧០៨.៦០.២៥

៨៧០៨.៧០.១២ ៨៧០៨.៧០.១៣ ៨៧០៨.៧០.១៤ ៨៧០៨.៧០.១៥ ៨៧០៨.៧០.៩២

៨៧០៨.៧០.៩៣ ៨៧០៨.៧០.៩៤ ៨៧០៨.៧០.៩៥ ៨៧០៨.៨០.១២ ៨៧០៨.៨០.១៣

៨៧០៨.០.១៤ ៨៧០៨.៨០.១៥ ៨៧០៨.៨០.៩២ ៨៧០៨.៨០.៩៣ ៨៧០៨.៨០.៩៤

៨៧០៨.៨០.៩៥ ៨៧០៨.៩១.២០ ៨៧០៨.៩១.៣០ ៨៧០៨.៩១.៤០ ៨៧០៨.៩១.៥០

៨៧០៨.៩២.១២ ៨៧០៨.៩២.១៣ ៨៧០៨.៩២.១៤ ៨៧០៨.៩២.១៥ ៨៧០៨.៩២.៩២

៨៧០៨.៩២.៩៣ ៨៧០៨.៩៣.៩៤ ៨៧០៨.៩២.៩៥ ៨៧០៨.៩៣.២០ ៨៧០៨.៩៣.៣០
៨៧០៨.៩៣.៤០ ៨៧០៨.៩៣.៥០ ៨៧០៨.៩៤.១២ ៨៧០៨.៩៤.១៣ ៨៧០៨.៩៤.១៤
៨៧០៨:៩៤.១៥ ៨៧០៨.៩៤.២២ ៨៧០៨.៩៤.២៣ ៨៧០៨.៩៤.២៤ ៨៧០៨.៩៤.២៥
៨៧០៨.៩៩.១២ ៨៧០៨.៩៩.១៣ ៨៧០៨.៩៩.១៤ ៨៧០៨.៩៩.១៥ ៨៧០៨.៩៩.២២
៨៧០៨.៩៩.២៣ ៨៧០៨.៩៩.២៤ ៨៧០៨.៩៩.២៥ ៨៧០៨.៩៩.៩២ ៨៧០៨.៩៩.៩៣
៨៧០៨.៩៩.៩៤ និង ៨៧០៨.៩៩..៩៥ ។

**ឆ. ៣៣,៣៣ ភាគរយ** : សំរាប់ភេសជ្ជៈ និងផលិផលគេលសិលា ដែលមានទីតាំងរងលេខ ÷

២២០៤.១០.០០ ២២០៤.២១.១១ ២២០៤.២១.១២ ២២០៤.២១.២១ ២២០៤.២១.២២
២២០៤.២១.៣១ ២២០៤.២១.៣២ ២២០៤.២៩.១១ ២២០៤.២៩.១២ ២២០៤.២៩.២១
២២០៤.២៩.២២ ២២០៤.២៩.៣១ ២២០៤.២៩.៣២ ២២០៤.៣០.១០ ២២០៤.៣០.២០
២២០៥.១០.១០ ២២០៥.១០.២០ ២២០៥.៩០.១០ ២២០៥.៩០.២០ ២២០៨.២០.១០
២២០៨.២០.២០ ២២០៨.២០.៣០ ២២០៨.២០៤០ ២២០៨.៣០.១០ ២២០៨.៣០.២០
២២០៨.៤០.១០ ២២០៨.៤០.២០ ២២០៨.៥០.១០ ២២០៨.៥០.២០ ២២០៨.៦០.១០
២២០៨.៦០.៣០ ២២០៨.៧០.១០ ២០៨.៧០.២០ ២៧១០.០០.២១ ២៧១០.០០.២២
២៧១០.០០.២៣ ២៧១០.០០.២៤ ២៧១០.០០.២៥ និង ២៧១០.០០.២៦ ។

**ជ. ៤៥ ភាគរយ** : សំរាប់រថយន្ត ដែលមានទីតាំងរងលេខ ÷ ៨៧០៣.១០.១០

៨៧.០៣.១០.២០ ៨៧.០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២
៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ ៨៧០៣.៩០.១១
៨៧០៣.៩០.១២ ៨៧១១.២០.២០ ៨៧១១.៣០.០០ ៨៧១១.៤០.០០ ៨៧១១.៥០.០០
៨៧១១.៩០.២០ ទំនិញដែលមាននៅក្នុងទីតាំងលេខ ៨៩.០៣ ទំនិញដែលមានទីតាំងលេខ ៩៣.០២ ដល់ ៩៣.០៧ (លើកលែងតែទំនិញដែលមានទីតាំងរងលេខ ៩៣០៥.៩០.១០ ៩៣០៦.៣០.១០ ៩៣០៦.៣០.៣០ និង ៩៣០៦.៩០.១០)
និងទំនិញដែលមានទីតាំងលេខ ៩៥.០៤ ។

**ឈ. ៨០ ភាគរយ** : សំរាប់រថយន្តទេសចរណ៍ ដែលមានទីតាំងរងលេខ ÷

៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ និង ៨៧០៣.៣៣.២២ ។

ញ. ១១០ ភាគរយ : សំរាប់រថយន្តទេសចរណ៍ ដែលមានទីតាំងរងលេខ ÷ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨០៣.៣៣.៣១ និង ៨៧០៣.៣៣.៣២ ។

**មាត្រា ២.-** អត្រាពន្ធនាំចូលនៃទំនិញមួយចំនួន ដែលមានចែងក្នុងតារាងពន្ធគយកម្ពុជាជាធរមាន ត្រូវបានកែប្រែដូចខាងក្រោម ÷

**ក. ៣៥ ភាគរយ :** សំរាប់រាល់បណ្តាមុខទំនិញ ដែលមានអត្រាពន្ធចំនួន ៣០% ៤០% ៥០% ៩០% និង ១២០% ។

**ខ. ១៥ ភាគរយ :** សំរាប់រាល់បណ្តាមុខទំនិញ ដែលមានអត្រាពន្ធនាំចូលចំនួន ១០% និង ២០% និងទំនិញ ដែលមានទីតាំងលេខ ៨៣.១១ ។

**គ. ៧ ភាគរយ :** សំរាប់រាល់បណ្តាមុខទំនិញនៅក្នុងជំពូកទី ១០ ទាំងអស់ (លើកលែងតែទំនិញ ដែលមានទីតាំងរងលេខ÷ ១០០៥.១០.០០ ១០០៦.១១.០០ ១០០៨.៣០.០០) និងទំនិញដែលមានទីតាំងរងលេខ ១១០៤.១១.០០ ១១០៤.១២.០០ ១១០៤.១៩.៩០ ១១០៤.២១.០០ ១១០៤.២២.០០ ១១០៤.២៩.០០ ១១០៤.៣០.០០ ១១០៧.១០.០០ ២៧១៣.១២.០០ ២១៣.២០.០០ ២៧១៣.៩០.០០ ៥៦០១.១០.០០ ៦៣០៦.១១.០០ ៦៣០៦.១២.០០ និង ៦៣០៦.១៩.០០ ។

**ឃ. ០ ភាគរយ :** សំរាប់រាល់បណ្តាមុខទំនិញ ដែលមានអត្រាពន្ធនាំចូល ០.៣% និងទំនិញដែលមាន ទីតាំងរងលេខ ១០០៨.៣០.០០ ។

**មាត្រា ៣.-** អត្រាអាករនាំចេញនៃទំនិញមួយចំនួន ដែលបានចែងក្នុងតារាងពន្ធគយកម្ពុជាជាធរមាន ត្រូវបានកែប្រែដូចខាងក្រោម ÷

**ក.** **១០ ភាគរយ** : សំរាប់បណ្តាទំនិញ ដែលមានទីតាំងលេខ ០១.០១ ០១.០៦ ០៥.០៧ ជំពូកទី ៤១ ទាំងអស់ និងទំនិញដែលមានទីតាំងរងលេខ ៩៦០១.១០.១០ ៩៦០១.១០.៩០ និង ៩៦០១.៩០.០០ ។

**ខ.** **៥ ភាគរយ** : សំរាប់បណ្តាទំនិញមួយចំនួន ដែលមានទីតាំងរងលេខ ÷ ៤៤២០.៩០.០០ ៩៤០៣.៣០.០០ ៩៤០៣.៤០.០០ ៩៤.០៣.៥០.១០ ៩៤០៣.៥០.៩០ ៩៤០៣.៦០.២០ និង ៩៤០៣.៦០.៩០ ។

**គ.** **០ ភាគរយ** : សំរាប់បណ្តាទំនិញមួយចំនួន ដែលមានទីតាំងលេខ ០១.០៣ ។

**មាត្រា ៤.-** ត្រូវបានបន្ថែមទំនិញមួយមុខទៀត ដោយដាក់ទីតាំងរងលេខ ៧៣១៥.១១.០០ (ច្រវ៉ាក់កង់ឬម៉ូតូ) ដែលត្រូវជាប់ពន្ធនាំចូល ៧% អាករពិសេស ០% អាករលើតំលៃបន្ថែមលើការនាំចូល ១០% និងអាករនាំចេញ ០% ។

**មាត្រា ៥.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

* * *

# អនុក្រឹត្យលេខ ៤៥ អនក្រ.បក

## ស្តីពី

## ការបង្កើតក្រុមការងារជាន់ខ្ពស់

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០០/១៩២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យា គមនាគមណ៍ពត៌មានវិទ្យា

យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-** បង្កើតក្រុមការងារជាន់ខ្ពស់មួយ ដើម្បីសំរបសំរួលការងារគំរោង បច្ចេកវិទ្យា គមនាគមណ៍ពត៌មានវិទ្យា ក្នុងក្របខ័ណ្ឌជំនួយមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចពីសាធារណរដ្ឋកូរ៉េ ៦មួយអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមពត៌មាន វិទ្យា និងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២-ឯកឧត្តម **ឡា ណារ៉ាត** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិក

៣-ឯកឧត្តម **ត្រាក់ ថៃសៀង** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរងទី១ រាជធានីភ្នំពេញ ជាសមាជិក

៤-លោក **អ៊ុំ ជុនហួរ** អគ្គនាយករងក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៥-លោក **ហង្ស វិបុលចន្ទ្រា** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខក្រសួងមហាផ្ទៃ ជាសមាជិក

៦-លោក **ឡោ ដារុង** ប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

**មាត្រា ២.-** ក្រុមការងារនេះដំណើរការ ការងារក្រោមការដឹកនាំរបស់ប្រធាន រឺ សមាជិកណាម្នាក់ដែលប្រធានប្រគល់សិទ្ធិឱ្យ ។

**មាត្រា ៣.-** ក្នុងករណីចាំបាច់ ប្រធានក្រុមការងារបច្ចេកទេសជាន់ខ្ពស់ អាចលើកសំណើបំពេញបន្ថែមសមាជិករបស់ខ្លួនតាមតំរូវការជាក់ស្តែង។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមអគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកការងារអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមណ៍ ពត៌មានវិទ្យា ឯកឧត្តម អស់លោកតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៤៦ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា

តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១.–** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣.៧០៥លានរៀល (បីពាន់ប្រាំពីររយប្រាំលានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមក

ជំពូក ១០ (បៀវត្ស និងប្រាក់បំណាច់) ចំនួន ៥២៥លានរៀល . ជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ចំនួន ៣.០០០លានរៀល និង មកជំពូក ៣១ (អន្តរាគមណ៍ក្នុង វិស័យ សង្គមកិច្ច និង វប្បធម៌) ចំនួន ១៨០លានរៀល របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់ គ្រងឆ្នាំ ២០០១។

**មាត្រា ២.-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយលើប្រាក់ម៉ោងសាស្ត្រាចារ្យ. ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី និង អាហារូបករណ៍និស្សិត វគ្គបណ្តុះបណ្តាលបរិញ្ញាប័ត្រជាន់ខ្ពស់ ជំនាន់ទី ១ នៅរាជបណ្ឌិតសភាកម្ពុជា។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ២២៩ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ប្រធានមូលនិធិអភិវឌ្ឍណ៍មុស្លីមកម្ពុជា :

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនក្នុងនិងក្រៅប្រទេស ០៤រូប ដែលបានបរិច្ចាគថវិកា ក្នុងការកសាងវិហារឥស្លាម (**ម៉ាស្ជិឧត្តរលហ្វីដាយម៉ាស់**) នៅភូមិព្រៃពិស ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយមានខាងក្រោមនេះ :

១-លោក **ហាជ្ជីមហាំម៉ាត់ ពិនឧស្មឆ្មាន** អ៊ីម៉ាស្ទិទ ទឹកប្រាក់ចំនួន ១០.៥៥៨ USD

២-លោក **អាស្តារី ពិនហាជ្ជីអះម៉ាត់** បច្ចុប្បន្ននៅប្រទេសកាតារ៉ា ទឹកប្រាក់ចំនួន ១១.១០០ USD

៣-លោក **អាប់ឌុលរ៉ាសាក់ ពិនហាជ្ជីអ៊ីស្មាឯល** បច្ចុប្បន្នរស់នៅប្រទេសម៉ាឡេស៊ី ទឹក ប្រាក់ចំនួន ១០.០០០ USD

៤-លោក **ហាជ្ជីអាដាំ ពិនអាលី** ទឹកប្រាក់ចំនួន ១០.៤០០ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អភិបាលខេត្តកំពង់ឆ្នាំង និងប្រធានមូលនិធិ អភិវឌ្ឍណ៍ មុស្លិមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ២៣០ អនក្រ.តត

## ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ដែលជាតំណាងអង្គការក្រៅរដ្ឋាភិបាល ចំនួន០២រូប បានចូលរួមជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ ទីចាត់ការ បង្គន់ របងសាលា នៅក្នុងសាលាបឋមសិក្សាអង្គខ្នារ ឃុំខ្នារ ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :

១-លោក **សាកាម៉ូតូ (Mr. SAKAMOTO)** ប្រធានក្លិបលីយ៉ុង ( President of Utsunomiya Futaara Lions Club and Lioness Club ) ចំណាយថវិកា ចំនួន ១៣.៥៥០ ដុល្លារអាមេរិក

២-លោក **យ៉ាស្ទីនបាយវើស (Mr. JUSTIN BYWORTH)** នាយកអង្គការទស្សនៈពិភពលោកប្រចាំនៅកម្ពុជា (Director of World Vision Cambodia) ចំណាយថវិកា ចំនួន ១៣.១០០ ដុល្លារអាមេរិក

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

# អនុក្រឹត្យលេខ ២៣១ អនក្រ.តត
## ស្ដីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេីច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគមនៃប្រទេសជប៉ុន ចំនួន ០៣ អង្គ ភាព ដែលបានជួយសាងសង់អាគារសិក្សា ០១ខ្នង មាន ០៨បន្ទប់ បង្គន់អនាម័យ តុសិស្ស តុគ្រូ របងសាលា និងសំភារៈសិក្សាមួយចំនួន ដល់សាលាបឋមសិក្សាជន្លង់ ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :

១-SUNA BASHY PORT LYON CLUB ទឹកប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក

២-SUNA BASHY SAZANGKA LYON CLUB ទឹកប្រាក់ចំនួន២០.០០០ ដុល្លារអាមេរិក

៣-SUNA BASHY LYON CLUB ទឹកប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

* * *

**អនុក្រឹត្យលេខ ២៣២ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយការងារ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីគារបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក លោកស្រី ជាប្រធាន អនុប្រធានមន្ទីរជុំវិញខេត្តកណ្តាល ចំនួន ០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក តាមមុខជំនាញ ដូចមានរាយនាមខាងក្រោម :

១-លោក **យ៉ិន ញ៉ឹម** ប្រធានមន្ទីរពត៌មានខេត្ត

២-លោក ជន់ ម៉េងឡុង ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត

៣-លោក តុប សន ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត

៤-លោក ទាវ សារឿន ប្រធានសាខាពន្ធដារខេត្ត

៥-លោកស្រី គង់ សារិយ៉ា អនុប្រធានមន្ទីរពតិមានខេត្ត

៦-លោក សាយ សុផល អនុប្រធានសាខាពន្ធដារខេត្ត

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ២៣៣ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា
- យោងតាមសំណូមពរការងារ ចាំបាច់

**សំរេច**

**មាត្រា ១.-** តែងតាំងមន្ត្រីរាជការ ចំនួន ០៥រូប នៃរាជបណ្ឌិតសភាកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | **សោម សុមុនី** | ជាអនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រ មានឋានៈស្មើ អគ្គនាយករង |
| ២-លោកស្រី | **ខ្លូត ធីតា** | ជាអនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានឋានៈស្មើ អគ្គនាយករង |
| ៣-លោក | **អ៊ាប ម៉ុណ្ណា** | ជាលេខាធិការអចិន្ត្រៃយ៍ វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៤-លោក | **ជូ ច័ន្ទដារី** | ជាប្រធានផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៥-លោក | **ត្រឹង លីម** | ជាប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានឋានៈស្មើ ប្រធាននាយកដ្ឋាន |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ និងរាជបណ្ឌិតសភាកម្ពុជា ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ២៣៤ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**ប្រការ ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឡៅ ហេង** និងលោកស្រី **តាន់ សាយឃុត** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនក្នុងការកសាងអាគារសិក្សា ០១ខ្នង មាន ០៣បន្ទប់ បំពាក់សំភារៈសិក្សា មានតុ កៅអីសិស្ស តុគ្រូ និងក្តារខៀនគ្រប់បន្ទប់ នៅវិទ្យាល័យសម្តេចឪ ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

**អនុក្រឹត្យលេខ ២៣៥ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកព/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់**មេដាយមុនីសារាភ័ណ្ឌថ្នាក់"ធិបឌិន្ទ"** ជូនលោកឧកញ៉ា **ម៉ុត គីមស៊ាន** ដែលបានខិតខំយកចិត្តទុកដាក់យ៉ាងសកម្ម ក្នុងការលើកស្ទួយវិស័យព្រះពុទ្ធសាសនា ក្នុងខេត្តបាត់ដំបង ដោយកសាងថ្មីទាំងស្រុង វត្តរុំមស៊ីប្រសិទ្ធីរាម ហៅវត្ត សមសាន្ត នៅភូមិដង្កោទាប ឃុំទួលតាឯក ស្រុកបាត់ដំបង ចំណាយអស់ទឹកប្រាក់ ២៩០.៨២៦ ដុល្លារអមេរិក និងកសាងសមិទ្ធផលជាច្រើន នៅក្នុងវត្តខាងលើ មានតម្លៃជាទឹកប្រាក់ប្រមាណ ២០.០០០ ដុល្លារអាមេរិក ព្រមទាំងជួយប្រជាជនរងគ្រោះមហន្តរាយផ្សេងៗ និងចំណាយអស់ទឹកប្រាក់ជាច្រើនទៀត។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៣៦ អនក្រ.តត
# ស្តីពី
# ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ចំនួន ០៥រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា និងអភិវឌ្ឍន៍សង្គមនៅស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

១- លោក **កែវ ណារិន** កសាងសាលាធម្មសភា ០១ខ្នង និងរោងបាយ ០១ខ្នង អស់ទឹកប្រាក់ ចំនួន ៣៣.០០០ USD

២- ឧបាសក **ស៊ើន អ៊ុំ** កសាងសាលាមត្តេយ្យ០១ខ្នង ជួសជុលវត្តពោធិលង្ការ កាច់រទេះ សាងសង់ឈាបនដ្ឋាន បង្គន់អនាម័យ និងអាគារសិក្សា ០១ខ្នង មាន ០៣ បន្ទប់ អស់ទឹកប្រាក់ ចំនួន ២០.០៨២ USD

៣- លោក **ឃួន ភណ្ឌៀង** ប្រធានសមាគមសណ្តោសខ្មែរនៅសហរដ្ឋអាមេរិក កសាងសមិទ្ធផលជាច្រើនលើវិស័យព្រះពុទ្ធសាសនា និងវិស័យអប់រំ នៅក្នុងវត្តកំពង់ព្រះ ស្រុកសង្កែ អស់ទឹកប្រាក់ ចំនួ ១២.៣៨៨ USD

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១- លោកស្រី **ជឿន ចន្ថា** បរិច្ចាគថវិកាចូលរួមកសាងសមិទ្ធផលជាមួយលោក **កែវ ណារិន**

២- ឧបាសិកា **ផាង ភិន** បរិច្ចាគថវិកាចូលរួមកសាងសមិទ្ធផលជាមួយឧបាសក **ស៊ើន អ៊ឹ**

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ២៣៧ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់អ្នកតំណាងរាស្ត្រមណ្ឌលតាកែវ

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៤រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួនជួយសាងសង់អាគារសិក្សា ០១ខ្នង មាន ០៦បន្ទប់ និងជួសជុលអាគារសិក្សា ០៣ខ្នង មាន ០៦បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់នៅសាលាបឋមសិក្សាអង្គគោល ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :

**ក.-មេដាយមាសស្ថាបនាជាតិ :**

១- លោក **ខិម តារា** តំណាងអង្គការពុទ្ធិកសង្គ្រោះខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ ១២.០០០ USD

២- លោក **ឡោ ម៉ុនណារ៉ាត** តំណាងអង្គការ LWS ទឹកប្រាក់ ១០.៤២២ USD

**ខ.-មេដាយប្រាក់ស្ថាបនាជាតិ :**

១- លោក **ថោង ព្រឹង** នាយកសាលាបឋមសិក្សាអង្គគោល ទឹកប្រាក់ ៩.០០០ USD

២- លោក **អ៊ុយ សំនៀង** តំណាងអង្គការពុទ្ធិកសង្គ្រោះខ្មែរប្រចាំព្រះរាជាណាចក្រកម្ពុជា ទឹកប្រាក់ ៨.៧៨០ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៣៨ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើររបស់អ្នកតំណាងរាស្ត្រមណ្ឌលតាកែវ

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និងជូនសប្បុរសជន ០៩រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួនជួយសាងសង់ព្រះវិហារវត្តអង្គខ្នារ ឃុំអង្គខ្នារ ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោម ÷

**ក.-មេដាយមាសស្ថាបនាជាតិ :**

១- ព្រះឃោសាវិសុទ្ធិរាជាគណៈ **កែ យ៉ាន់** ចៅអធិការវត្តមុន្នីសុវណ្ណចំពុះក្អែក

| | | | |
|---|---|---|---|
| | | បច្ច័យ | ២៨.០០០ USD |
| ២- លោក | **ភួង ហ៊ត** | ទឹកប្រាក់ | ១៣.០០០ USD |
| ៣- លោក | **ម៉ែន វណ្ណា** | ទឹកប្រាក់ | ១២.០០០ USD |

**ខ.-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- ឧបាសិកា | **ឌុំ ស៊ីវគី** | ទឹកប្រាក់ | ៧.៥០០ USD |

២- អ្នកស្រី **យិន ឡេង** ទឹកប្រាក់ ៧.៥០០ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ២៣៩ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់អភិបាលខេត្តកោះកុង

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និងជូនសប្បុរសជន ០៥រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅក្នុង

វត្តសំរោង ប្រសិទ្ធិវិទ្ធ វត្តសាមគ្គីគីរីស្ទឹងឆាយ និងវត្តឧត្តមមុន្នីវង្ស ស្រុកកំពង់សិលា ខេត្តកោះកុង ដូចមានរាយ ព្រះនាម និងនាមខាងក្រោមនេះ :

**ក. មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **សេង គឹមឡេង** ព្រះបាឡាត់គណខេត្ត បច្ច័យចំនួន ១០.១០៥ USD

២-លោកស្រី **សេង ផល្លីន** នៅភូមិស្ទឹងសំរោង ទឹកប្រាក់ចំនួន ១៣.០១០ USD

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ម៉ៅ មួន** ប្រធានគណៈកម្មការវត្តប្រសិទ្ធិវិទ្ធ ទឹកប្រាក់ចំនួន ៥.៧០០ USD

**គ. មេដាយសំរិទ្ធស្ថាបនាជាតិ :**

១- លោក **ឆាយ ដាងហេង** មេឃុំអូរបាក់រទេះ ទឹកប្រាក់ចំនួន ៣.៦០០ USD

២- លោក **ថោង ចន្ថា** អាចារ្យវត្តសំរោងប្រសិទ្ធិ វិទ្ធទឹកប្រាក់ចំនួន២.៩៣៥ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ២៤០ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ហ៊ីដេអូ អូម៉ូរី** (HIDEO OHMORI) និងភរិយា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនក្នុងការកសាងអាគារសិក្សា ០១ខ្នង មាន ០៣បន្ទប់ និងបំពាក់សំភារៈសិក្សា មានតុ កៅអីសិស្ស តុគ្រូ និងក្តារខៀនគ្រប់បន្ទប់ នៅសាលាបឋមសិក្សាគោកសេះ ឃុំភ្នំដី ស្រុកភ្នំស្រុក ខេត្តបន្ទាយជ័យ ចំណាយអស់ទឹកប្រាក់ ១៣.៥៥៨.៧៥ ដុល្លារអាមេរិក។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

**អនុក្រឹត្យលេខ ២៤១ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយមុនីសារាភ័ណ្ឌ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេីច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កេីត និងប្រេីប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណេីរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយមុនីសារាភ័ណ្ឌ (ថ្នាក់សេនា)** ប្រគេនជូនព្រះសង្ឃ អាចារ្យវត្តចំនួន ០៣រូប ដែលបានខិតខំប្រឹងប្រែងយកអស់កំលាំងកាយពល ចូលរួមកសាងព្រះវិហារវត្តសូរ្យច័ន្ទ ស្ថិតនៅឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ដូចមានរាយនាមជូនខាងក្រោម :

១-ព្រះតេជគុណ **ជឿស ខិម**

២-ព្រះតេជគុណ **ឆឹម សុវន្នា**

៣-លោកតា **សែស ស៊ឹម**

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

===

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

## អនុក្រឹត្យលេខ ២៤២ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ០៩រូប ដែល បានបរិច្ចាគធនធានផ្ទាល់ ចូលរួមកសាងព្រះវិហារ វត្តសូរ្យច័ន្ទ ឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ដូចមានរាយនាមជូនខាងក្រោម :

ក-មេដាយមាសស្ថាបនាជាតិចំនួន ០៦រូប

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ឃិន** | **ម៉េន** | ១២.០០០ USD |
| ២-លោក | **គីម** | **សុខុម** | ១១.០០០ USD |
| ៣-លោក | **តែ** | **តាំងប៉ះ** | ១១.០០០ USD |
| ៤-លោកស្រី | **ចាន់** | **សុខ្ញា** | ១០.៥០០ USD |
| ៥-លោក | **លី** | **ហុក** | ១០.០០០ USD |
| ៦-លោក | **គីម** | **ឈាន** | ១០.០០០ USD |

ខ-មេដាយប្រាក់ស្ថាបនាជាតិ ចំនួន ០៣រូប :

១-លោក ម៉ុំ ព្រិច ៥.៥០០ USD

២-លោក សួខ ទាសនា ៥.០០០ USD

៣-លោក នូ សេដ្ឋា ៥.០០០ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

**អនុក្រឹត្យលេខ ២៤៣ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ០១រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមជួយសាងសង់សាលារៀន ០២ខ្នង មាន ១០បន្ទប់ ព្រះវិហារ កុដិ ក្លោងទ្វារ របង និងផ្លូវ នៅវត្តអង្គរុន ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ៖

ក-មេដាយមាសស្ថាបនាជាតិ ៖

១- ព្រះតេជគុណ **ង៉ែត ផល្លា** ព្រះគ្រូចៅអធិការវត្តអង្គរុន បច្ច័យ ចំនួន ១១.២៤៤ USD

២- មហាឧបាសក **ហ៊ុន នាង** ថវិកាចំនួន ១៦.៥០០ USD

៣-លោក **លឹម សម្បត្តិ** ថវិកាចំនួន ១៦.៧៤៥ USD

៤- លោកយាយ **យិន គៀម** ថវិកាចំនួន ១៥.៨៧៥ USD

៥- លោកយាយ **ឃឹម អ៊ួច** ថវិកាចំនួន ១៣.៥០៨ USD

៦- លោក **ហង់ សាមឿន** ថវិកាចំនួន ១២.៩៣៣ USD

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ ៖

១-ឧបាសក **អ៊ុំ ហ៊ាង** ថវិកាចំនួន ២.៤៥០ USD

២-លោក **ធឹម អ៊ុយ** ថវិកាចំនួន ១.៦០០ USD

៣-លោក **ហេង ឿន** ថវិកាចំនួន ១.៥០០ USD

៤-លោក **តុត តួន** ថវិកាចំនួន ១.៥០០ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ២៤៤ អនក្រ.តត
## ស្ដីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជាកិច្ចបច្ឆាមរណៈជូនសពលោក **ភិត ម៉ុនថន** អធិការនគរបាលស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និងលោក **ម៉ុក ប៉ូលី** មន្ត្រីបច្ចេកទេស នៃនាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលមានស្នាដៃ និងគុណ បំណាច់ខ្ពង់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ ហើយបានទទួលមរណភាពក្នុងពេលបំពេញបេសកកម្មចុះ វាស់វែងព្រំដែន កម្ពុជា-ឡាវ ក្នុងខេត្តស្ទឹងត្រែង ។

**មាត្រា ២.-** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៤៥ អនក្រ.តត

## ស្តីពី

## ការជូនមេដាយការងារ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេីច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយប្រាក់ការងារ** ជូនមន្ត្រីបច្ចេកទេសចំរុះព្រំដែនកម្ពុជា-ឡាវ និងកងការពារព្រំដែននៃយុទ្ធភូមិភាគ I ចំនួន ០៤រូប ដែលបានខិតខំពុះពារគ្រប់ការលំបាក និងធ្វើពលីកម្មគ្រប់បែបយ៉ាង ក្នុងបុព្វហេតុជាតិមាតុភូមិ រហូតទទួលរងនូវគ្រោះថ្នាក់ជាទម្ងន់ក្នុងពេលបំពេញបេសកកម្មចុះវាស់វែងព្រំដែនកម្ពុជា-ឡាវ ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក **ឡាយ សៀវលី** ប្រធានក្រុមបច្ចេកទេសចំរុះព្រំដែនកម្ពុជា-ឡាវ នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

២-លោកអនុសេនីយ៍ឯក **ភួយ សុធី** មន្ត្រីបច្ចេកទេសចំរុះព្រំដែនកម្ពុជា-ឡាវ នៃក្រសួងមហាផ្ទៃ

៣-លោក **ង៉ាត ម៉ុនសឿន** វរ: ១០១ កងការពារព្រំដែន នៃយោធភូមិភាគ I

៤-លោក **ឌី តាណាយ** វរ: ១០១ កងការពារព្រំដែន នៃយោធភូមិភាគ I

**មាត្រា ២.-** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទិ ៣១ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

## ២.សេចក្ដីប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០១

### សេចក្ដីប្រកាសលេខ ០២ ស.ប្រក

### ស្ដីពី

### កាលបរិច្ឆេទនៃការចាប់ផ្ដើមពិនិត្យបញ្ជីឈ្មោះ អ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា ឃុំ សង្កាត់

***

យោងតាមវាក្យខ័ណ្ឌទី២ មាត្រា ៤៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៣០១-០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ។

ផ្អែកតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លេខ ៦១៥ ល.ស ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១។

រាជរដ្ឋាភិបាលកម្ពុជា សំរេចកំណត់យកថ្ងៃ សៅរ៍ ទី ២១ ខែ កក្កដា ឆ្នាំ ២០០១ ជាកាលបរិច្ឆេទនៃការចាប់ផ្ដើមពិនិត្យឈ្មោះអ្នកបោះឆ្នោត និងចុះបញ្ជីអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# III- ការងារបណ្ដាក្រសួង

## ១_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

**ប្រកាសលេខ ០១២/០១ ទរ.ពរអ.ប្រក**

**ស្ដីពី**

**ការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត_ក្រុង**

* * *

**រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

-យោងតាមការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត-ក្រុង ជាសេនាធិការអោយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររបស់មន្ទីរ

-រៀបចំស្ថិតិ លើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

-រៀបចំការងារបៀវត្ស ពលកម្ម ប្រាក់កំរៃ និងរបបធានារ៉ាប់រងសង្គម ក្នុងសមត្ថកិច្ចរបស់មន្ទីររៀបចំ ចងក្រង គ្រប់គ្រងប្រព័ន្ធទិន្នន័យ ស្ថិតិ និងលើកផែនការការងារទូទៅរយៈពេលខ្លី មធ្យម និងវែង លើគ្រប់ផ្នែកទាំងអស់ ក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីលើកជូនក្រសួងពិនិត្យ និងសំរេច

-ប្រមូលផ្តុំតំរូវការ លើកគំរោង ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ

-គ្រប់គ្រងចនលទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ ប្រេងឥន្ធនៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-សំរបសំរួល និងទំនាក់ទំនងរាល់ការងារ រវាងអាជ្ញាធរខេត្ត-ក្រុង ជាមួយសមាជិករដ្ឋសភា ព្រឹទ្ធសភា ក្នុងមណ្ឌលខេត្ត-ក្រុងរបស់ខ្លួន

-សិក្សាស្រាវជ្រាវច្បាប់ដែលចូលជាធរមាន និងបណ្តាលិខិតបទដ្ឋានគតិយុត្តិ របស់រាជរដ្ឋាភិបាល ផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងមណ្ឌលខេត្ត-ក្រុងរបស់ខ្លួនអោយយល់ដឹង និងប្រតិបត្តិតាម

-ទទួលពាក្យបណ្តឹង ពិនិត្យសមត្ថកិច្ច និងចាត់បញ្ជូនទៅស្ថាប័ន ឬ អង្គភាពដែលមានភារកិច្ចពិនិត្យ និងដោះស្រាយ អោយបានត្រឹមត្រូវតាមថិរវេលាកំណត់

-អង្កេតស្រាវជ្រាវបណ្តឹង ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន

-លើកផែនការធ្វើអធិការកិច្ច តាមការណែនាំរបស់ក្រសួង សំដៅប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា

-អញ្ជើញជនដែលពាក់ព័ន្ធ តាមរយៈសមត្ថកិច្ចដែលគ្រប់គ្រងជនទាំងនោះ ដើម្បីមកបំភ្លឺ សាកសួរស្រាវស្រាវពតិមានផ្តល់ឯកសារ និងចូលរួមសហការក្នុងសកម្មភាពអង្កេតស្រាវជ្រាវ ឬ ធ្វើ អធិការកិច្ច

-លើកសំណើ សុំអោយក្រសួងចេញសេចក្តីសំរេច ផ្អាកជាបណ្តោះអាសន្នចំពោះការអនុវត្តណ៍ ទាំងឡាយណា ដែលបានពិនិត្យឃើញថា បង្កនូវមហន្តរាយធ្ងន់ធ្ងរ ប៉ះពាល់ដល់ផល ប្រយោជន៍ជាតិ សាធារណៈ និងទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋ

-កសាងសំណុំរឿងដាក់ជូនក្រសួង ដើម្បីសុំការសំរេចពីប្រមុខរាជរដ្ឋាភិបាល បញ្ជូនទៅ តុលាការធ្វើការវិនិច្ឆ័យទោសតាមច្បាប់ ចំពោះរូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ដែលបានប្រព្រឹត្ត ល្មើសច្បាប់ ឬ អនុវត្តខុសពីតួនាទី ធ្វើអោយប៉ះពាល់ដល់ទំនាក់ទំនងកិច្ចអធិការដ្ឋ ឬ ប្រើសិទ្ធិអំណាចបង្កការ រាំងស្ទះក្នុងពេលធ្វើអធិការកិច្ច

-សរុប និងធ្វើរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារផ្សេងៗរបស់មន្ទីរជូនក្រសួង.

**ប្រការ ២ :** មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត-ក្រុង ដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានជាជំនួយការ ដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួង ។

**ប្រការ ៣ :** មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មានការិយាល័យចំណុះចំនួន ០៤ ដូចខាងក្រោម :

ការិយាល័យរដ្ឋបាល កិច្ចការទូទៅ

ការិយាល័យទំនាក់ទំនងអាជ្ញាធរខេត្ត-ក្រុង នឹងសមាជិករដ្ឋសភា ព្រឹទ្ធសភា

ការិយាល័យអធិការកិច្ច

**ប្រការ ៤ :** ការិយាល័យនីមួយៗ ជាសេនាធិការអោយមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ចខេត្ត-ក្រុង មានភារកិច្ច :

**១.ការិយាល័យ រដ្ឋបាលកិច្ចការទូទៅ :**

-សំរបសំរួល សកម្មភាពគ្រប់ផ្នែករបស់មន្ទីរនៅថ្នាក់ខេត្ត និងរវាងថ្នាក់ខេត្ត និងក្រសួង

-គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់មន្ទីរ

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់មន្ទីរ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

-រៀបចំការងារបៀវត្ស ពលកម្ម ប្រាក់កំរៃ និងរបបធានារ៉ាប់រងសង្គម

-លើកផែនការការងារទូទៅរយៈពេលខ្លី មធ្យម និងវែង

-តាមដានត្រួតពិត្យលិខិតបទដ្ឋាន និងបទបញ្ញត្តិនានារបស់ថ្នាក់លើ

-ប្រមូលផ្តុំតំរូវការលើកគំរោងថ្វិកាវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ ប្រេងឥន្ធនៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-សរុប និងធ្វើរបាយការណ៍ អំពីសកម្មភាព និងលទ្ធផលការងារផ្សេងៗរបស់មន្ទីរ ។

**២-ការិយាល័យ ទំនាក់ទំនងរដ្ឋបាលខេត្ត-ក្រុង និងសមាជិករដ្ឋសភា ព្រឹទ្ធសភា :**

សំរបសំរួល និងទំនាក់ទំនងការងាររវាងអាជ្ញាធរខេត្ត-ក្រុង និងសមាជិករដ្ឋសភា ព្រឹទ្ធ សភាក្នុងមណ្ឌលខេត្ត-ក្រុងរបស់ខ្លួន

សិក្សាស្រាវជ្រាវច្បាប់ដែលបានចូលជាធរមាន និងលិខិតបទដ្ឋានគតិយុត្តិនានា របស់រាជរដ្ឋាភិបាល

ផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋក្នុងមណ្ឌលខេត្ត-ក្រុងរបស់ខ្លួន អោយយល់ដឹង និងប្រតិបត្តិតាម ។

**៣-ការិយាល័យ ទទួលពាក្យបណ្តឹង និង អង្កេតស្រាវជ្រាវ :**

-ទទួលពាក្យបណ្តឹង ពិនិត្យសមត្ថកិច្ច និងចាត់បញ្ជូនទៅស្ថាប័ន ឬ អង្គភាពមានភារកិច្ច ពិនិត្យ និងដោះស្រាយតាមថិរវេលាកំណត់

-តាមដានជំរុញការអនុវត្តណ៍លទ្ធផលនៃការដោះស្រាយបណ្តឹងរបស់ពលរដ្ឋ

-អង្កេតស្រាវជ្រាវបណ្តឹង ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន តាមការឯកភាពយល់ព្រមពីក្រសួង ។

**៤-ការិយាល័យ អធិការកិច្ច :**

ក្តាប់សភាពការណ៍ក្នុងមណ្ឌលខេត្ត-ក្រុងរបស់ខ្លួន លើកផែនការសុំអនុញ្ញាតពីក្រសួង ÷

-ធ្វើអធិការកិច្ច លើការងារដឹកនាំគ្រប់ក្រសួង ចំណូល-ចំណាយ ថវិកាជាតិ

-ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ

-ការគ្រប់គ្រងប្រើប្រាស់ជំនួយជាតិ អន្តរជាតិ

-ការប្រព្រឹត្តិអំពើពុករលួយ រំលោភដោយអំណាច និងបាតុភាពអសកម្មនានា

-តាមដានការអនុវត្តណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា ដែលក្រសួងប្រគល់អោយ ។

**ប្រការ ៥ :** ការិយាល័យនិមួយៗ ដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានជាជំនួយការ ព្រម ទាំងមានមន្ត្រីមួយចំនួនជាសហការី ។

ប្រធាន អនុប្រធាន និងមន្ត្រីនៃការិយាល័យនីមួយៗ ត្រូវជ្រើសរើសចេញពីមន្ត្រីក្របខ័ណ្ឌ មុខងារសាធារណៈ និងត្រូវបានតែងតាំងទទួលស្គាល់ដោយប្រកាសរបស់ក្រសួង ។

**ប្រការ ៦ :** សេក្តីកំណត់ទាំងឡាយ ដែលផ្ទុយពីបទប្បញ្ញត្តិក្នុងប្រការនៃប្រកាសនេះ ត្រូវទុកជា និរាករណ៍ ។

**ប្រការ ៧ :** ខុទ្ទកាល័យ រក្តនាយកដ្ឋាន នាយកដ្ឋាន ក្រោមឱវាទក្រសួង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**យូន ហ៊ាន**

***

ឧបសម្ព័ន្ធនៃប្រកាសលេខ ០១២/០១ នរពអ.ប្រក. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០១

អង្គការលេខនៃមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ខេត្ត~ក្រុង



## ២-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

### ប្រកាសលេខ ៦៥ ផក.ប្រក

### ស្តីពី

### ការប្រើប្រាស់កំរងទិន្នន័យមូលដ្ឋានឃុំ-សង្កាត់

* * *

### រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ
- បានឃើញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មន្ទីរផែនការខេត្ត-ក្រុងលេខ ២៣២ផក.ប្រក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០០

យោងតាមតម្រូវការចាំបាច់

### សំរេច

**ប្រការ ១ :** គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវជួយមន្ត្រីដឹកនាំមូលដ្ឋានភូមិ ឃុំ-សង្កាត់ នៅតាមខេត្ត-ក្រុងរបស់ខ្លួន ក្នុងការប្រមូលចងក្រងទិន្នន័យមូលដ្ឋាលភូមិ ឃុំ-សង្កាត់។

**ប្រការ ២ :** ក្នុងការជួយមន្ត្រីដឹកនាំមូលដ្ឋានភូមិ ឃុំ-សង្កាត់ ធ្វើការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវប្រើកំរងសំនួរទិន្នន័យមូលដ្ឋាន ឃុំ-សង្កាត់ ដែលមាន ៧៧ សំណួរ តាមគំរូភ្ជាប់មកជាមួយ។

**ប្រការ ៣ :** គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវប្រើប្រាស់ឯកសារណែនាំអំពីខ្លឹមសារសំណួរក្នុងកំរងសំណួរទិន្នន័យមូលដ្ឋានភូមិ-ឃុំ-សង្កាត់ ដែលរៀបចំឡើងដោយក្រសួងផែនការ ដូចមានភ្ជាប់មកជាមួយប្រកាសនេះ សំរាប់ធ្វើការប្រមូលយកពត៌មានទិន្នន័យមូលដ្ឋានពីភូមិ ឃុំ-សង្កាត់ ។

**ប្រការ ៤ :** យោងតាមតំរូវការពត៌មានសំរាប់ការងារអភិវឌ្ឍន៍ខេត្ត-ក្រុងរបស់ខ្លួនផ្ទាល់ គ្រប់មន្ទីរផែនការខេត្ត-ក្រុង អាចធ្វើការប្រមូលពត៌មានទិន្នន័យភូមិ ឃុំ-សង្កាត់ បន្ថែមលើ ៧៧សំណួរ ។ សំណួរដែលបន្ថែមនោះ រក្សាទុកត្រឹមថ្នាក់ខេត្ត-ក្រុង ដោយពុំបាច់ផ្ញើមកក្រសួងផែនការឡើយ ។

**ប្រការ ៥ :** ការប្រមូល និងចងក្រងកំរងទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវអនុវត្តន៍តាមជំហ៊ានការងារ និងកាលបរិច្ឆេទដែលបានកំណត់ និងផ្ញើកំរងទិន្នន័យមូលដ្ឋាននោះ មកអគ្គនាយកដ្ឋានផែនការផ្នែកកម្មវិធីសិលា ដើម្បីចាត់ចែងការងារបន្ត ។

**ប្រការ ៦ :** គំរូកំរងទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ ដែលបានប្រើតាមរយៈប្រកាសលេខ ២៦ ផក ។ ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់ក្រសួងផែនការ ត្រូវចាត់ទុកនិរាករណ៍ ។

**ប្រការ ៧ :** អគ្គនាយកផែនការ នាយវិទ្យាស្ថានជាតិស្ថិតិ អគ្គាធិការនៃក្រសួងផែនការ គ្រប់ប្រធាននាយកដ្ឋានជំនាញក្រោមឱវាទក្រសួងផែនការ គ្រប់ប្រធានមន្ទីរផែនការខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះឱ្យបានល្អប្រសើរតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ឆាយ ថន**

***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * *

# សៀវភៅទិន្នន័យភូមិ

ភូមិ : ........................................................ លេខកូដភូមិសាស្ត្រ : ........................................................

ឃុំ : ........................................................ ស្រុក : ........................................................

ខេត្ត : ........................................................

ឆ្នាំ ..................................

**បញ្ជីសំណួរ**

| លេខរ | សំណួរ | ចំនួន |
|---|---|---|
| ១ | ចំនួនគ្រួសារសរុបក្នុងភូមិ | |
| ២ | ចំនួនមនុស្សស្រីសរុប | |
| ៣ | ចំនួនមនុស្សប្រុសសរុប | |
| ៤ | ចំនួនក្មេងស្រី អាយុពី ០ ដល់ ៤ ឆ្នាំ ( ក្រោម ៥ឆ្នាំ) | |
| ៥ | ចំនួនក្មេងប្រុស អាយុពី ០ ដល់ ៤ ឆ្នាំ ( ក្រោម ៥ឆ្នាំ) | |
| ៦ | ចំនួនក្មេងស្រី អាយុពី ៥ ដល់ ១៤ ឆ្នាំ | |
| ៧ | ចំនួនក្មេងប្រុស អាយុពី ៥ ដល់ ១៤ឆ្នាំ | |
| ៨ | ចំនួនស្ត្រីអាយុពី ៦៥ ឆ្នាំឡើង | |
| ៩ | ចំនួនបុរសអាយុពី ៦៥ឆ្នាំឡើង | |
| ១០ | ចំនួនក្មេងស្រីអាយុពី ៥ ដល់ ១៤ ឆ្នាំ ដែលមានចូលរៀន | |
| ១១ | ចំនួនក្មេងប្រុសអាយុពី ៥ ដល់ ១៤ ឆ្នាំ ដែលបានចូលរៀន | |
| ១២ | ចំនួនអនក្ខរជនភេទស្រី ដែលមានអាយុលើសពី ១៥ ឆ្នាំ | |
| ១៣ | ចំនួនអនក្ខរជនភេទប្រុសដែលមានអាយុលើសពី ១៥ ឆ្នាំ | |
| ១៤ | ចំនួនមនុស្សស្រីបាត់បង់សមត្ថភាពពលកម្ម | |
| ១៥ | ចំនួនមនុស្សប្រុសបាត់បង់សមត្ថភាពពលកម្ម | |
| ១៦ | ចំនួនកុមារកំព្រាអាយុតិចជាង ១៥ ឆ្នាំ | |
| ១៧ | ចំនួនកុមារាកំព្រាអាយុតិចជាង ១៥ ឆ្នាំ | |
| ១៨ | ចំនួនគ្រួសារដែលមានមេគ្រួសារជាស្ត្រី | |
| ១៩ | ចំនួនគ្រួសារប្រកបរបរដាំដុះជាចំណូលសំខាន់ | |
| ២០ | ចំនួនគ្រួសារកសិករដាំដុះលើដីផ្ទាល់ខ្លួន | |
| | **គេហដ្ឋាន** | **ចំនួន** |
| ២១ | ចំនួនផ្ទះថ្ម | |

| | | |
|---|---|---|
| ២២ | ចំនួនផ្ទះឈើ | |
| ២៣ | ចំនួនផ្ទះស្លឹក | |
| ២៤ | ចំនួនផ្ទះដែលមានអគ្គិសនី ( ១១០.២២០វ៉ុល) | |
| | **ការអប់រំ** | **ចំនួន** |
| ២៥ | ចំនួនបន្ទប់សាលាបឋមសិក្សានៅក្នុងភូមិ | |
| ២៦ | ចំនួនបន្ទប់សាលាមធ្យមសិក្សានៅក្នុងភូមិ | |
| ២៧ | ចំនួនគ្រូបឋមសិក្សា | |
| ២៨ | ចំនួនគ្រូមធ្យមសិក្សា | |
| ២៩ | ចំនួនថ្នាក់អក្ខរកម្ម | |
| ៣០ | ចំនួនបន្ទប់រៀននៃសាលាមត្តេយ្យសិក្សា | |
| | **សុខភាព** | **ចំនួន** |
| ៣១ | ចំនួនភ្នាក់ងារសុខាភិបាលនៅក្នុងភូមិ | |
| ៣២ | ចំនួនគ្រូខ្មែរដែលមានក្នុងភូមិ | |
| ៣៣ | ចំនួនឆ្មបបុរាណដែលមានក្នុងភូមិ | |
| ៣៤ | ចំនួនឆ្មបដែលបានបណ្ដុះបណ្ដាលមាននៅក្នុងភូមិ | |
| ៣៥ | ចំនួនកុមារអាយុពី ០-៥ឆ្នាំ ស្លាប់រយៈពេល ១២ខែមុន | |
| ៣៦ | ចំនួនស្ត្រីស្លាប់បន្ទាប់ពីសំរាលកូនបាន ២៨ថ្ងៃ ( គិត១២ខែកន្លងមក) | |
| | **ទឹកស្អាត និងអនាម័យ** | **ចំនួន** |
| ៣៧ | ចំនួនអណ្ដូងលូដែលប្រើបានគ្រប់រដូវ | |
| ៣៨ | ចំនួនអណ្ដូងជីកដោយដៃដែលប្រើបានគ្រប់រដូវ | |
| ៣៩ | ចំនួនអណ្ដូងស្នប់ដែលប្រើបានគ្រប់រដូវ | |
| ៤០ | ចំនួនស្រះទឹកហូបដែលអ្នកភូមិប្រើប្រាស់ | |
| ៤១ | ចំនួនបង្គន់អនាម័យដែលប្រើការកើត | |

| | **ដឹកជញ្ជូន** | **ចំនួន** |
|---|---|---|
| ៤២ | ចំនួនម៉ូតូ | |
| ៤៣ | ចំនួនត្រាក់ទ័រ គោយន្ត រថយន្ត | |
| ៤៤ | ចំនួនរទេះគោ និងរទេះសេះ | |
| ៤៥ | ចំនួនកង់ | |
| ៤៦ | ចំនួនទូកចែវ/អុំ | |
| ៤៧ | ចំនួនទូកម៉ាស៊ីន/កាណូត | |
| ៤៨ | ចំងាយពីភូមិទៅផ្សារដែលនៅជិតបំផុត ( គិតជាគីឡូម៉ែត្រ) | |
| ៤៩ | ចំងាយពីភូមិទៅផ្លូវដែលនៅជិតបំផុតដែលអាចបើកឡានចេញចូលពេញ ១ឆ្នាំ ( គិតជាគីឡូម៉ែត្រ) | |
| ៥០ | ចំងាយពីភូមិទៅសាលាមធ្យមសិក្សាជិតបំផុត ( គិតជាគ ។ម) | |
| ៥១ | ចំងាយពីភូមិទៅមណ្ឌលសុខភាពឃុំជិតបំផុត ( គិតជាគ ។ម) | |
| | **ធនធានកសិកម្ម** | **ចំនួន** |
| ៥២ | ផ្ទៃដីស្រែវស្សា ( គិតជាហិកតា) | |
| ៥៣ | ផ្ទៃដីស្រែវស្សាបង្កើនរដូវ ( គិតជាហិកតា) | |
| ៥៤ | ផ្ទៃដីស្រែបាំងប្រដេញទឹក ( គិតជាហិកតា) | |
| ៥៥ | ផ្ទៃដីស្រែប្រាំងស្រោចស្រព ( គិតជាហិកតា) | |
| ៥៦ | ផ្ទៃដីស្រូវចំការ ( គិតជាហិកតា) | |
| ៥៧ | ផ្ទៃដីដាំដុះដំណាំផ្សេងៗទៀត ( គិតជាហិកតា) | |
| ៥៨ | ផ្ទៃដីមានមីន ( គិតជាហិកតា) | |
| ៥៩ | ចំនួនអណ្តូងទឹកស្រោចស្រព | |
| | **ផលិតផលក្នុងឆ្នាំ** | **ចំនួន** |
| ៦០ | ផលិតផលស្រូវសរុបក្នុងរយៈពេល ១២ខែ កន្លងមក ( គិតជាតោន) | |
| ៦១ | ផលិតផលពោតសរុបក្នុងរយៈពេល ១២ខែ កន្លងមក ( គិតជាតោន) | |

| | ការចិញ្ចឹមសត្វ | ចំនួន |
|---|---|---|
| ៦២ | ចំនួនគោ-ក្របី ដែលមិនមែនជាកំលាំងអូសទាញមានក្នុងភូមិ | |
| ៦៣ | ចំនួនគោ-ក្របីដែលជាកំលាំងអូសទាញមានក្នុងភូមិ | |
| ៦៤ | ជ្រូកមាននៅក្នុងភូមិ | |
| ៦៥ | ចំនួនភ្នាក់ងារពេទ្យសត្វនៅក្នុងភូមិ | |
| | **សេដ្ឋកិច្ចជនបទ** | **ចំនួន** |
| ៦៦ | ចំនួនកន្លែងផ្តល់សេវាកម្មកសិកម្ម | |
| ៦៧ | ចំនួនកន្លែងផលិតកម្មកសិកម្មជនបទ | |
| ៦៨ | ចំនួនកន្លែងផលិតកម្មសិប្បកម្មជនបទ | |
| ៦៩ | ចំនួនសេវាកម្ម និងតូបលក់ទំនិញនានា | |
| | **ទ្រព្យសម្បត្តិគ្រួសារ** | **ចំនួន** |
| ៧០ | ចំនួនទូរទស្សន៍ | |
| | **ការចាកចេញពីភូមិទៅរកការធ្វើ** | **ចំនួន** |
| ៧១ | ចំនួនមនុស្សស្រីចាកចេញពីភូមិទៅរកការងារធ្វើ | |
| ៧២ | ចំនួនមនុស្សប្រុសចាកចេញពីភូមិទៅរកការងារធ្វើ | |
| | **ការរៀបចំតាមសហគមន៍ជនបទ** | **ចំនួន** |
| ៧៣ | ចំនួនក្រុមឥណទានប្រាក់ | |
| ៧៤ | ចំនួនក្រុមធនាគារសត្វ | |
| ៧៥ | ចំនួនក្រុមធនាគារស្រូវ | |
| ៧៦ | ចំនួនក្រុមប្រើប្រាស់ទឹកហូប | |
| ៧៧ | ចំនួនក្រុមកសិករប្រើប្រាស់ទឹកស្រោចស្រព | |

សំគាល់ :

សំណួរទាំងប៉ុន្មានខាងលើនេះ មិនអនុញ្ញាតអោយធ្វើការផ្លាស់ប្តូរលេខរៀង ឬ ខ្លឹមសារ បើមាន ករណីចាំបាច់ ខេត្តអាចបន្ថែមសំណួរនៅក្នុងតារាងបន្ទាប់ ។

បើគ្មានចំនួនតួលេខស្ថិតិទេ ត្រូវបំពេញចំលើយសូន្យ តែបើមានដែរ តែប្រធានភូមិភ្លេចឆ្លើយ ឬ ពុំ ច្បាស់លាស់ សូមកុំបំពេញលេខសូន្យជំនួសប្រធានភូមិអោយសោះ សូមទុកចំហរចោល ឬ ធ្វើការបញ្ជាក់ជា មួយប្រធានភូមិម្តងទៀត ។

’ ប្រធានភូមិ មេឃុំ និងមន្ត្រីផែនការស្រុក ត្រូវចុះហត្ថលេខា និងឈ្មោះលើខ្នងសៀវភៅនេះ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវជាផ្លូវការចំពោះតួលេខស្ថិតិដែលខ្លួនបានបំពេញ ។

ខ្នាតចំងាយត្រូវគិតជាគីឡូម៉ែត្រ ខ្នាតផ្ទៃដីត្រូវគិតជាហិកតា ផលិតផលសរុបត្រូវគិតជាតោន ដើម្បី អោយមានការឯកភាពទូទាំងប្រទេស ។

## សំណួរបន្ថែមតាមខេត្តនិមួយៗ

| លេខ | សំណួរ | ចំនួន |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

ឆ្នាំទី ៩ លេខ ២០ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១ រាជកិច្ច ទំព័រ ១៤៦១ .

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * *

# សេចក្តីណែនាំខ្លឹមសារសំណួរ

ក្នុង

# សៀវភៅទិន្នន័យភូមិ

**ក្រសួងផែនការ**

**២០០១**

## ជំពូក ១ : ស្ថិតិភូមិ

**១. ចំនួនគ្រួសារសរុបក្នុងភូមិ :** ជាចំនួនគ្រួសារដែលរស់នៅអចិន្ត្រៃយ៍ក្នុងភូមិ ដោយមិនគិតពីគ្រួសារដែលស្នាក់នៅបណ្តោះអាសន្ន ហើយនិងត្រូវវិលត្រឡប់ទៅភូមិកំណើតវិញក្នុងពេលឆាប់ៗ ឡើយ ។

**គ្រួសារ :** គ្រួសារមួយគឺជាមនុស្សមួយក្រុម ដែលរស់នៅជាមួយគ្នា ហើយបរិភោគបាយដែលចេញពី ចង្ក្រានរួម ហើយចាយវាយថវិការួមគ្នា តែចំណូលបានមកផ្សេងៗពីគ្នា ។

**២. ចំនួនមនុស្សស្រីសរុប :** ចំនួនស្ត្រីសរុបរស់នៅក្នុងភូមិ ដោយមិនគិតអាយុទាំងចាស់ ទាំងក្មេង ។

**៣. ចំនួនមនុស្សប្រុសសរុប :** ចំនួនបុរសសរុបរស់នៅក្នុងភូមិ ដោយមិនគិតអាយុទាំងចាស់ទាំងក្មេង ។

**៤. ចំនួនក្មេងស្រីអាយុពី ០ ដល់ ៤ឆ្នាំ (ក្រោម៥ឆ្នាំ ) :** ចំនួនក្មេងស្រីទាំងអស់ អាយុក្រោម ៥ឆ្នាំ គិតត្រឹមថ្ងៃស្រង់ស្ថិតិ ។

**៥. ចំនួនក្មេងប្រុសអាយុពី ០ ដល់ ៤ឆ្នាំ (ក្រោម៥ឆ្នាំ) :** ក្មេងប្រុសទាំងអស់អាយុក្រោម ៥ឆ្នាំ គិតត្រឹមថ្ងៃស្រង់ស្ថិតិ ។

**៦. ចំនួនក្មេងស្រីពី ៥ឆ្នាំ ដល់ ១៤ឆ្នាំ :** គឺជាចំនួនក្មេងស្រីដែលមានអាយុពី៥ឆ្នាំ រហូតដល់ ១៤ឆ្នាំ នៅក្នុងភូមិ (ក្រោម១៥ឆ្នាំ) ។

**៧. ចំនួនក្មេងប្រុសពី៥ឆ្នាំ ដល់១៤ឆ្នាំ :** ជាចំនួនក្មេងប្រុសដែលមានអាយុពី ៥ឆ្នាំពេញ រហូតដល់ ១៤ឆ្នាំ ។

**៨. ចំនួនស្ត្រីអាយុពី ៦៥ឆ្នាំឡើង :** ជាចំនួនស្ត្រីអាយុពី ៦៥ឆ្នាំឡើងទៅនៅក្នុងភូមិ ។

**៩. ចំនួនបុរសអាយុពី ៦៥ឆ្នាំឡើង :** ជាចំនួនមនុស្សប្រុសអាយុពី ៦៥ឆ្នាំឡើងទៅនៅក្នុងភូមិ ។

**១០. ចំនួនក្មេងស្រីពី ៥ឆ្នាំ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន :** ជាចំនួនក្មេងស្រីចាប់ពីអាយុ ៥ឆ្នាំពេញ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន (ពីមត្តេយ្យឡើងទៅ) ។

**១១. ចំនួនក្មេងប្រុសពី ៥ឆ្នាំ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន :** ជាចំនួនក្មេងប្រុសចាប់ពីអាយុ ៥ឆ្នាំពេញ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន (ពីមត្តេយ្យឡើងទៅ) ។

១២. **ចំនួនអនក្ខរជនភេទស្រីដែលមានអាយុពី១៥ឆ្នាំឡើង** : សំណួរនេះត្រូវរាស់កំរិតមិនចេះអក្សរឱ្យបានដូចៗគ្នាគ្រប់ខេត្តទូទាំងប្រទេស ។ ស្ត្រីមិនចេះអក្សរ ដែលស្រង់គឺជាចំនួនមនុស្សស្រីចាប់ពីអាយុ១៥ឆ្នាំឡើង ដែលមិនអាចអានអត្ថបទបានត្រឹមត្រូវពី៥ទៅ៦បន្ទាត់ និងសរសេរអក្សរមិន បានពី ៣ ទៅ ៥បន្ទាត់ ។

១៣. **ចំនួនអនក្ខរជនភេទប្រុសដែលមានអាយុលើសពី ១៥ឆ្នាំ** : ដូចគ្នានិងសំណួរខាងលើដែរ ដោយ គ្រាន់តែប្តូរមកជាចំនួនមនុស្សប្រុសវិញ ។

១៤. **ចំនួនស្រីបាត់បង់សមត្ថភាពពលកម្ម** : សំណួរនេះសំដៅយកស្ត្រីណាដែលបាត់បង់អវៈយវៈសរីរាង្គ ឬ វិញ្ញាណណាមួយដែលមានពីកំណើត ឬ ដោយសារជំងឺ សង្គ្រាម ឬ គ្រោះថ្នាក់ផ្សេងៗទៀត ។ ទោះបីមានមនុស្សពិការខ្លះមានលទ្ធភាពជួយធ្វើការគ្រួសារខ្លះក៏ដោយ ក៏ត្រូវរាប់បញ្ចូល ដែរ តែចំពោះមនុស្សចាស់អាយុចាប់ពី ៦៥ឆ្នាំឡើងទៅ មិនត្រូវរាប់បញ្ចូលទេ ។

១៥. **ចំនួនមនុស្សប្រុសបាត់បង់សមត្ថភាពពលកម្ម** : (ដូចសំណួរទី ១៤) គ្រាន់តែប្តូរពីស្រីមកប្រុសប៉ុណ្ណោះ ។

១៦. **ចំនួនកុមារីកំព្រាអាយុតិចជាង ១៥ឆ្នាំ** : គឺជាចំនួនកុមារកំព្រា ភេទស្រី មានសរុបក្នុងភូមិ ។ កុមារកំព្រា គឺជាកុមារដែលមានអាយុតិចជាង ១៥ឆ្នាំ ហើយបាត់បង់ទាំងឪពុក ទាំងម្តាយ ដោយស្លាប់ ឬ បាត់ដំណឹងយូរមកហើយគ្មានអ្នកថែរក្សាគ្រប់គ្រង ។ កូនចិញ្ចឹមមិនរាប់បញ្ចូលថាជាកុមារកំព្រាឡើយ ។

១៧. **ចំនួនកុមារ កំព្រាអាយុតិចជាង១៥ឆ្នាំ** : (ដូចសំណួរទី១៦ គ្រាន់តែប្តូរពីក្មេងស្រីមកក្មេងប្រុស) ។

១៨. **ចំនួនគ្រួសារដែលមានមេគ្រួសារជាស្រី** : មេគ្រួសារ គឺជាមនុស្សមួយរូប ដែលគេទទួលស្គាល់ថាជាមេនៅក្នុងគ្រួសារ ។ ចំពោះមេគ្រួសារជាស្ត្រីនេះ គឺមានស្ត្រីជាអ្នកទទួលខុសត្រូវចាត់ចែងក្នុងគ្រួសារ ហើយធ្វើសេចក្តីសំរេចកិច្ចការនានាក្នុងនាមគ្រួសារ ។

១៩. **ចំនួនគ្រួសារដែលប្រកបរបរដាំដុះជាចំណូលសំខាន់** : គឺជាចំនួនសរុបគ្រួសារកសិករក្នុងភូមិដែលបានប្រកាន់យកការដាំដំណាំ ឬ ធ្វើស្រែចំការជាប្រភពចំណូលសំខាន់សំរាប់ចិញ្ចឹមគ្រួសារ ដោយមិនគិតថា គ្រួសារនោះមានមុខរបរបន្ទាប់បន្សំច្រើនផ្សេងទៀត ឬ គ្មាននោះទេ ។

**២០.គ្រួសារកសិករដាំដុះលើដីផ្ទាល់ខ្លួន :** ចេញពីចំនួនគ្រួសារក្នុងសំណួរខាងលើ សំរាប់គ្រួសារណាដែលធ្វើស្រែចំការតែលើដីផ្ទាល់ខ្លួនប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលគ្រួសារដែលខ្លួនឯងគ្មានដីដាំដុះសោះ ហើយទៅជួលគេមកធ្វើការដាំដុះ ។

## ជំពូក ២ : គេហដ្ឋាន

**២១. ចំនួនផ្ទះថ្ម :** គឺជាផ្ទះដែលសង់ឡើងអំពីថ្ម ឬ ឥដ្ឋ យើងគិតបញ្ចូលជាផ្ទះថ្មដែរ ប្រសិនបើផ្ទះនោះខាងក្រោមថ្ម ខាងលើឈើ ដោយមិនគិតដំបូល ។

**២២. ចំនួនផ្ទះឈើ :** គឺជាចំនួនផ្ទះដែលសង់ឡើងដោយសរសរឈើ ដែលមានជញ្ជាំងបាំងធ្វើអំពីក្តារ ទោះមានរៀបថ្មជាបន្ទប់ខាងក្រោមបន្តិចបន្តួច ក៏រាប់ជាផ្ទះឈើដែរ ដោយមិនគិតពីដំបូល ។

**. ចំនួនផ្ទះស្លឹក :** គឺជាចំនួនផ្ទះដែលសង់ឡើងដោយសរសរឈើ តែជញ្ជាំងស្លឹក ដំបូលស្លឹក ទោះជាផ្ទះមានជញ្ជាំងបាំងអំពីក្តារបន្តិចបន្តួច ក៏គិតជាផ្ទះស្លឹកដែរ ។ គិតបញ្ចូលទាំងផ្ទះបណ្តែតទឹក និងយកទូកធ្វើ ជាផ្ទះនៅជាប្រចាំផងដែរ ប្រសិនបើគ្រួសារគាត់ត្រូវបានរាប់បញ្ចូលជាគ្រួសារដែលរស់នៅអចិន្ត្រៃយ៍ ក្នុងភូមិដូចក្នុងសំណួរទីមួយខាងលើដែរ ។

**២៤. ចំនួនផ្ទះដែលមានអគ្គិសនី(១១០.២២០វុល) :** ជាចំនួនសរុបនៃផ្ទះទាំងអស់ដែលប្រើប្រាស់ចរន្តអគ្គិសនី ១១០-២២០វុល ទោះជាអគ្គិសនីរដ្ឋ ឬ ឯកជនក៏ដោយ ។

## ជំពូក ៣ : ការអប់

**២៥. ចំនួនបន្ទប់សាលាបឋមសិក្សាសរុបនៅក្នុងភូមិ :** ចំនួនបន្ទប់រៀនបឋមសិក្សាកំពុងប្រើប្រាស់មានទីតាំងនៅក្នុងភូមិ ។

**២៦.ចំនួនបន្ទប់សាលាមធ្យមសិក្សាសរុបនៅក្នុងភូមិ :** ចំនួនបន្ទប់រៀនមធ្យមសិក្សាកំពុងប្រើប្រាស់ានទីតាំងនៅក្នុងភូមិ ។

**២. ួនគ្រូបឋមសិក្សា :** ចំនួនគ្រូបង្រៀនដែលកំពុងបង្រៀននៅសាលាបឋមសិក្សាក្នុងភូមិ គិតទាំងគ្រូជាប់កិច្ចសន្យាផងដែរ ប៉ុន្តែពុំរាប់បុគ្គលិកការិយាល័យទេ ។ បើគ្រូនោះមិនបានបង្រៀននៅសាលានៅក្នុងភូមិ គឺមិនត្រូវរាប់ទេ ព្រោះនាំអោយត្រួតតួលេខដែលភូមិមួយទៀតបានរាប់បញ្ចូលរួចទៅហើយ ។

**២៨. ចំនួនមធ្យមមធ្យមសិក្សា** : ចំនួនគ្រូបង្រៀនដែលកំពុងបង្រៀននៅសាលាមធ្យមសិក្សាក្នុងភូមិ, គិត ទាំងគ្រូជាប់កិច្ចសន្យាផងដែរ ប៉ុន្តែពុំរាប់បុគ្គលិកការិយាល័យទេ។ ដូចគ្នានិងសំណួរខាងលើ ដើម្បីជៀសវាងការចុះត្រួតគ្នាលេខ។

**២៩. ចំនួនថ្នាក់អក្ខរកម្ម** : ចំនួនថ្នាក់បង្រៀនអក្សរដល់មនុស្សពេញវ័យ ឬ មនុស្សចាស់ ដែលមាននៅក្នុងភូមិ ទោះជាអង្គការ ឬ ស្ថាប័នណាបង្កើតក៏ដោយ។

**៣០. ចំនួនបន្ទប់រៀនមត្តេយ្យសិក្សា** : ចំនួនបន្ទប់មត្តេយ្យសិក្សាមានក្នុងភូមិ។

## ជំពូក ៤ : សុខភាព

**៣១. ចំនួនភ្នាក់ងារសុខាភិបាលនៅក្នុងភូមិ** : គឺជាចំនួនជនស្ម័គ្រចិត្តនៅក្នុងភូមិ ដែលបានបណ្តុះបណ្តាលដោយសុខាភិបាលខេត្ត-ក្រុង ខាងផ្នែកអប់រំសុខភាពបឋមនៅក្នុងភូមិ។ បើភ្នាក់ងារនេះមកពីភូមិដទៃ មិនត្រូវរាប់បញ្ចូលទេ ព្រោះវាអាចត្រួតគ្នាលេខគ្នា ។

**៣២. ចំនួនគ្រូខ្មែរដែលមានក្នុងភូមិ** : ចំនួនគ្រូខ្មែរដែលព្យាបាលជម្ងឺដោយផ្សំថ្នាំតាមបែបបុរាណ ពី ឫស មើម សំបក ស្លឹករុក្ខជាតិ មាននៅក្នុងភូមិទាំងអស់ ។

**៣៣. ចំនួនឆ្មបបុរាណដែលមានក្នុងភូមិ** : គឺជាឆ្មបពុំបានឆ្លងកាត់ការបណ្តុះបណ្តាលពីសាលាឆ្មបរដ្ឋ តែបានជួយបង្កើតកូននៅពេលអ្នកភូមិត្រូវការ។

**៣៤. ចំនួនពេទ្យឆ្មបដែលបានបណ្តុះបណ្តាលមាននៅក្នុងភូមិ** : គឺចំនួនឆ្មបដែលបានឆ្លងកាត់ការបណ្តុះបណ្តាលដោយសុខាភិបាលខេត្ត ឬ ក្រុង ។

**៣៥. ចំនួនកុមារអាយុ ០ ដល់ ៥ឆ្នាំ ស្លាប់ក្នុងរយៈពេល ១២ខែកន្លងមក** :

កុមារទាំងពីរភេទដែល បានស្លាប់ពីអាយុ ០ ដល់ ៥ឆ្នាំ នៅក្នុងរយៈ ១២ខែកន្លងមក។

**៣៦. ចំនួនស្ត្រីស្លាប់បន្ទាប់ពីសំរាលកូនបាន ២៨ថ្ងៃ (គិត១២ខែកន្លងមក)** :

ស្ត្រីឆ្លងទន្លេស្លាប់ គឺគិតតែក្នុងរយៈពេល ២៨ថ្ងៃ ក្រោយពីឆ្លងទន្លេប៉ុណ្ណោះ។ បើហួសពី ២៨ថ្ងៃ គឺមានន័យថាស្លាប់ ក្នុងករណីផ្សេងៗ មិនអាចរាប់បញ្ចូលបានទេ។

## [illegible]

**៣៧.ចំនួនអណ្តូងលូដែលប្រើប្រាស់បានគ្រប់រដូវ** : គឺអណ្តូងដែលជីកដាក់លូតាមក្បួនអនាម័យដែលប្រើបានគ្រប់រដូវ ( ឬមានទឹកគ្រប់រដូវ ) ។

**៣៨. ចំនួនអណ្តូងជីកដោយដៃដែលប្រើបានគ្រប់រដូវ** : គឺអណ្តូងដែលជីកហើយមិនដាក់ខ្ទោះ ( លូ ) ដែលអាចប្រើបានគ្រប់រដូវ ( មានទឹកគ្រប់រដូវ ) ។

**៣៩. ចំនួនអណ្តូងស្នប់ដែលប្រើបានគ្រប់រដូវ** : គឺអណ្តូងអង្គការនានា ឬ ស្ថាប័នផ្សេងៗធ្វើជូនដែលមាននៅក្នុងភូមិ ឬ ប្រជាជនជួលគេជីកប្រើប្រាស់ខ្លួនឯង ។

**៤០. ចំនួនស្រះទឹកហូបដែលអ្នកភូមិប្រើប្រាស់** : ស្រះទឹកសំរាប់ហូបរបស់ប្រជាជនក្នុងភូមិដែលរួមកំលាំងគ្នាជីកជាស្រះធំៗ ឬ ផ្តល់ដោយអង្គការនានា ឧទាហរណ៍ : ដូចជា ត្រពាំងតាវេត្ត ។

**៤១.ចំនួនបង្គន់អនាម័យដែលប្រើការកើត** : ចំនួនបង្គន់តាមលំនៅដ្ឋាន និងបង្គន់សាធារណៈដែលមានបិទបាំងជិតល្អ ហើយកំពុងប្រើប្រាស់សព្វថ្ងៃ ។

## [illegible]

**៤២. ចំនួនម៉ូតូ** : គឺជាម៉ូតូគ្រប់ប្រភេទដែលមាននៅក្នុងភូមិ ។ ទោះជាម៉ូតូរឺម៉កក៏ត្រូវចុះបញ្ចូលក្នុងសំណួរទី៤២ នេះដែរ ។

**៤៣. ចំនួនត្រាក់ទ័រ/គោយន្ត/រថយន្ត** : ចំនួនត្រាក់ទ័រ គោយន្ត និងរថយន្ត សរុបរួម ដែលកំពុងប្រើប្រាស់សព្វថ្ងៃនៅក្នុងភូមិ ។

**៤៤. ចំនួនរទេះសេះ និងចំនួនរទេះគោ** : ចំនួនសរុបនៃរទេះសេះ និងរទេះគោក្របីគ្រប់ប្រភេទ កំពុងប្រើប្រាស់នៅក្នុងភូមិ ។ រទេះសេះ គឺជារទេះគ្រប់ប្រភេទដែលអូសដោយកំលាំងសេះ ។ រទេះ គោ-ក្របី គឺជារទេះគ្រប់ប្រភេទ ដែលអូសដោយកំលាំងគោ-ក្របី ។

**៤៥. ចំនួនកង់** : គឺជាកង់គ្រប់ប្រភេទដែលប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរ ។ គិតទាំងកង់អូសរឺម៉កផងដែរ ។

**៤៦. ចំនួនទូកចែវ/អុំ** : គឺជាប្រភេទទូកដែលប្រើចែវ ឬ ច្រវ៉ា សំរាប់ជាមធ្យោបាយដឹកជញ្ជូនផ្លូវទឹកសំរាប់នេសាទ ឬ ចំលងអ្នកដំណើរក្នុងរង្វង់ទិជិតៗ ។

៤៧. **ចំនួនទូកម៉ាស៊ីនកាណូត** : ចំនួនទូកប្រើប្រាស់រុញដោយកំលាំងម៉ាស៊ីនតូចឬធំ ឬ ជាកាណូតសណ្តោង ។

៤៨. **ចំងាយពីភូមិទៅផ្សារដែលនៅជិតបំផុតគិតជាគីឡូម៉ែត្រ** : គឺជាចំងាយគិតពីចំណុចកណ្តាលភូមិ ទៅទីផ្សារដែលមានសកម្មភាពពិព្រលឹមដល់ព្រលប់ជាថ្ងៃរៀងរាល់ថ្ងៃ ឬមានសកម្មភាពរយៈពេលពី៦ម៉ោងទៅ៨ម៉ោង។ គិតជាគីឡូម៉ែត្រ។ បើផ្សារមានទីតាំងនៅក្នុងភូមិចំងាយគឺសូន្យគីឡូម៉ែត្រ។

៤៩. **ចំងាយពីភូមិទៅផ្លូវដែលនៅជិតបំផុតដែលអាចបើកឡានចេញចូលពេញមួយឆ្នាំ** : គឺចំងាយពីភូមិទៅផ្លូវដែលឡានអាចបើកចេញចូលបានពេញមួយឆ្នាំ។ គិតជាគីឡូម៉ែត្រ។ បើភូមិនៅជាប់ផ្លូវតែម្តង ចំងាយគឺសូន្យគីឡូម៉ែត្រ។

៥០. **ចំងាយពីភូមិទៅសាលាមធ្យមសិក្សាជិតបំផុត (គិតជាគម)** : គឺជាចំងាយគិតពីចំណុចកណ្តាលភូមិទៅដល់សាលាមធ្យមសិក្សានៅជិតបំផុត គិតជាគីឡូម៉ែត្រ។ បើសាលាមធ្យមសិក្សាមានទីតាំងនៅក្នុងភូមិចំងាយគឺសូន្យគីឡូម៉ែត្រ ។

៥១. **ចំងាយពីភូមិទៅមណ្ឌលសុខភាពឃុំនៅជិតបំផុត** : ជាចំងាយធ្វើដំណើរគិតពីចំណុចកណ្តាលភូមិទៅដល់មណ្ឌលសុខភាពឃុំ ដែលនៅជិតបំផុត គិតជាគីឡូម៉ែត្រ។ ប្រសិនបើមណ្ឌលសុខភាពឃុំនៅក្នុងភូមិ ត្រូវគិតជាចំងាយសូន្យគីឡូម៉ែត្រ។

## ជំពូក ៧ : ផលិតផលកសិកម្ម

៥២. **ផ្ទៃដីស្រែវស្សា** : គឺជាផ្ទៃដីស្រែវស្សា ដែលពឹងផ្អែកលើតែទឹកភ្លៀង ដោយគ្មានប្រព័ន្ធស្រោចស្រពធារាសាស្ត្រ ឬ អណ្តូងកសិកម្ម ហើយធ្វើបានម្តងក្នុង១ឆ្នាំ គិតជាហិកតា។

៥៣. **ផ្ទៃដីស្រែវស្សាបន្ថែមរដូវ** : គឺជាផ្ទៃដីស្រែវស្សាដែលពឹងផ្អែកលើទឹកភ្លៀង គ្មានប្រព័ន្ធស្រោចស្រពធារាស្ត្រ ឬអណ្តូងកសិកម្ម តែធ្វើបានលើសពីមួយដងក្នុងមួយឆ្នាំ គិតជាហិកតា។

៥៤. **ផ្ទៃដីស្រែប្រាំងស្រោចស្រព** : ជាផ្ទៃដីស្រែប្រាំងដែលមានប្រព័ន្ធស្រោចស្រព ឬ អណ្តូងកសិកម្មដែលអាចបង្កើតរដូវគិតជាហិកតា។

**៥៥-ផ្ទៃដីស្រែប្រាំងប្រដេញទឹក** : ជាផ្ទៃដីស្រែដែលធ្វើប្រដេញតាមទឹកស្រកទៅវិញនៅរដូវប្រាំង គិតជាហិកតា ។

**៥៦- ផ្ទៃដីស្រូវចំការគិតជាហិកតា** : គឺជាផ្ទៃដីដែលប្រជាជនធ្វើស្រូវ តាមបច្ចេកទេសដាំស្រូវចំការ គិត ជាហិកតា ។

**៥៧- ផ្ទៃដីដាំដុះផ្សេងៗទៀត** : ជាផ្ទៃដីសំរាប់ដាំដំណាំគ្រប់ប្រភេទដូចជា ពោត សណ្តែក ល្ង និងដំណាំចំការផ្សេងទៀត គិតជាហិកតា.......... ។ល ។

**៥៨- ផ្ទៃដីមានមីនគិតជាហិកតា** : ជាផ្ទៃដីដែលមានបង្កប់គ្រាប់មីនគ្រប់ប្រភេទមាននៅក្នុងភូមិ គិតជាហិកតា។

**សំគាល់** : រាល់ទំហំដីទាំងអស់ត្រូវគិតជាហិកតាដូចគ្នា។ ទោះជានៅតំបន់ខ្លះ គេនិយមប្រើជាអារ ឬ រ៉ៃ...... ក៏ដោយ ស្ថិតិត្រូវគិតជាខ្នាតហិកតាអោយរួចទើបចុះទៅក្នុងបញ្ជី។

**៥៩- ចំនួនអណ្តូងទឹកស្រោចស្រព** : គឺជាអណ្តូងទឹកដែលមានប្រភពពីធម្មជាតិ ឬ អណ្តូងកសិកម្មដែលមានប្រភពទឹកស្រោចស្រពមិនចេះរីងស្ងួត។

## ជំពូក ៨ : ផលិតផលក្នុងឆ្នាំ

**៦០-ផលិតផលស្រូវសរុបក្នុងរយៈពេល ១២ខែកន្លងមកគិតជាតោន** : គឺជាផលិតផលស្រូវសរុបទាំងអស់ ដែលអ្នកភូមិផលិតបានក្នុងរយៈពេល ១២ខែក្នុងកន្លងមក ។

**៦១-ផលិតផលពោតសរុបក្នុងរយៈពេល ១២ខែកន្លងមក គិតជាតោន** : គឺជាផលិតផលពោតគ្រប់ ប្រភេទសរុបទាំងអស់ ដែលអ្នកភូមិផលិតបានក្នុងរយៈពេល ១២ខែកន្លងមក ។

## ជំពូក ៩ : ការចិញ្ចឹមសត្វ

**៦២- ចំនួនគោក្របីដែលមិនមែនជាកំលាំងអូសទាញមានក្នុងភូមិ** : គឺជាចំនួនគោក្របីដែលប្រើប្រាស់ជាកំលាំងអូសទាញ ដែលមាននៅក្នុងភូមិ ហើយមិនបានប្រើប្រាស់ជាកំលាំងអូសទាញឡើយ.

**៦៣- ចំនួនគោក្របីដែលជាកំលាំងអូសទាញមានក្នុងភូមិ** : គឺជាចំនួនគោក្របី ដែលប្រើប្រាស់ជាកំលាំងអូសទាញ ដែលមាននៅក្នុងភូមិ ។

**៦៤. ចំនួនជ្រូកនៅក្នុងភូមិ** : គឺជាចំនួនជ្រូកដែលប្រជាជនចិញ្ចឹមសំរាប់យកសាច់ ឬ លក់និងយកកូនលក់មាននៅក្នុងភូមិ ។

**៦៥. ចំនួនភ្នាក់ងារពេទ្យសត្វនៅក្នុងភូមិ** : ជាភ្នាក់ងារល្អ ឬ ជនស្ម័គ្រចិត្តក្នុងភូមិ ដែលបានបណ្តុះបណ្តាលដោយមន្ទីរកសិកម្មខេត្ត-ក្រុង ។

## ជំពូក ១០ : សេដ្ឋកិច្ចភូមិ

**៦៦. ចំនួនកន្លែងផ្តល់សេវាកម្មកសិកម្ម** : ទីកន្លែងដែលលក់ ទិញ ឬ ផ្តល់សេវាកម្មកសិកម្មទាក់ទងទៅនិងស្រូវពូជបន្លែ ជី ឧបករណ៍-សំភារៈកសិកម្ម វ៉ាក់សាំង ថ្នាំសំលាប់សត្វល្អិត កូនត្រីជាដើម...........។ល។ (រាប់ចំនួនធ្វើអាជីវកម្មក្នុងផ្នែកនេះក្នុងឆ្នាំ) ។

**៦៧. ចំនួនកន្លែងផលិតកម្មកសិកម្ម** : ជាចំនួនទីកន្លែងដែលចិញ្ចឹមត្រី កង្កែប ទា មាន់ ឬ កសិដ្ឋានផ្សេងៗ........។ល។ (ដែលមិនមែនសំរាប់បរិភោគក្នុងគ្រួសារនោះទេ ប៉ុន្តែសំរាប់សជាចំណូលក្នុងគ្រួសារ) រាប់ចំនួនធ្វើអាជីវកម្មជាក់ស្តែងក្នុងឆ្នាំ។

**៦៨. កន្លែងផលិតកម្មសិប្បកម្មជនបទ** : ចំនួនអាជីវកម្មដែលបានដំណើរការផលិតផលក្នុងស្រុកផ្សេងៗ ដូចជា ទឹកត្នោតជូរ បិទស្រា ធ្វើទឹកកក ផលិតធ្យូង ជាងដែក ធ្វើទ្វារ បង្អួច ធ្វើនំបុ័ង កន្លែង ធ្វើធូប កន្លែងធ្វើឆ្នាំង/ក្អម/ថូ កន្លែងធ្វើចង្ក្រាន កន្លែងធ្វើពាងទឹក កន្លែងធ្វើប្រហុក/ផ្អក/មាំ...... ។ល។ រាប់ចំនួនអាជីវកម្មជាក់ស្តែងក្នុងឆ្នាំ ។

**៦៩. ចំនួនសេវាកម្មនិងតូបលក់ដូរផ្សេងៗនានា** : តូបផ្តល់សេវាផ្សេងៗនៅក្នុងភូមិ ដូចជាតូបកាត់សក់ អ៊ុតសក់ ជាងកាត់ដេរ ភោជនីយដ្ឋាន តូបលក់ចំណីអាហារ/ គ្រឿងទេស កន្លែងថតរូប លក់ថ្នាំ ពេទ្យ រោងជាងជួសជុលម៉ូតូ/កង់ ម៉ាស៊ីនចលករ ម៉ាញ៉េ ទូរទស្សន៍ បញ្ចូលអាគុយ សំអាងការ កន្លែងបញ្ចាំងវីដេអូ / ការ៉ាអូឃេ....... ។ល។

**សំគាល់** : ប្រសិនបើមានអ្នកធ្វើអាជីវកម្មណាមួយដែលត្រូវគ្នា និងរាល់សំណួរទាំងបួន សូមកត់ត្រាតែមួយបានហើយ ដោយរាប់បញ្ចូលទៅផ្នែកណាមួយ ដែលសំខាន់ជាងគេ នៅក្នុងអាជីវកម្មចំរុះរបស់ គាត់.

## ជំពូក ១១ : ទ្រព្យសម្បត្តិគ្រួសារ

**៧០. ចំនួនទូរទស្សន៍** : ជាទូរទស្សន៍គ្រប់ប្រភេទដែលកំពុងប្រើប្រាស់ក្នុងភូមិ ។

## ជំពូក ១២ : ការចាកចេញពីភូមិទៅរកការធ្វើ

**៧១-ចំនួនមនុស្សស្រីដែលចាកចេញពីភូមិទៅរកការធ្វើ** : ជាការចាកចេញរបស់មនុស្សស្រី ដើម្បីរកការងារធ្វើនៅខាងក្រៅភូមិរបស់ខ្លួនក្នុងរយៈពេលខ្លី ហើយមេភូមិនៅតែទទួលស្គាល់ថាជាប្រជាជននៅក្នុងភូមិរបស់គាត់។ អ្នកទៅបំរើការងារជាអចិន្ត្រៃយ៍ជាមួយក្រុមហ៊ុន ឬ អង្គការផ្សេងៗនៅភូមិ ចាប់ពី ៣ខែឡើងទៅ ហើយមេភូមិឈប់ទទួលស្គាល់ថាជាប្រជាជននៅក្នុងភូមិរបស់គាត់ គឺមិនត្រូវបានរាប់បញ្ចូលថាជាអ្នកចាកចេញទៅរកការងារធ្វើទេ។

**៧២- ចំនួនមនុស្សប្រុសដែលចាកចេញពីភូមិទៅរកការធ្វើ** : ដូចសំណួរ ៧១ (គ្រាន់តែប្តូរពីស្រីទៅប្រុស) ។

## ជំពូក ១៣ : ការរៀបចំការសហគមន៍ជនបទ

**៧៣- ចំនួនក្រុមឥណទានសាច់ប្រាក់** : ជាក្រុមដែលបានបង្កើតឡើងដោយអ្នកភូមិ ឬ អង្គការ ឬ ស្ថាប័នរដ្ឋ ដើម្បីសន្សំ និងខ្ចីប្រាក់ ។

**៧៤-ចំនួនក្រុមធនាគារសត្វ** : ជាក្រុមធនាគារសត្វដែលបានបង្កើតឡើង ដោយអ្នកភូមិ ឬ អង្គការនានា ឬស្ថាប័នរដ្ឋ ដូចជា ធនាគារជ្រូក ធនាគារគោក្របី ។ល.

**៧៥-ចំនួនក្រុមធនាគារស្រូវ** : ជាក្រុមធនាគារស្រូវដែលបានបង្កើតឡើងដោយអ្នកភូមិ ឬ អង្គការនានា ឬ ស្ថាប័នរដ្ឋ។ ធនាគារនេះអាចជាធនាគារស្រូវពូជ ឬ ស្រូវសំរាប់ហូប។

**៧៦- ចំនួនក្រុមប្រើប្រាស់ទឹកហូប** : ជាចំនួនក្រុមដែលប្រើប្រាស់ទឹកហូបបង្កើតឡើងដោយភាគច្រើនជាប្រជាជនក្នុងភូមិ ដែលមានការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល។ ឧទាហរណ៍ : នៅក្នុង ភូមិ (ក) មានពីរគ្រួសារមានអណ្តូងទឹកសំរាប់ប្រើប្រាស់ខ្លួនឯងតែដប់គ្រួសារទៀតគ្មានអណ្តូងទឹកប្រើប្រាស់ ដូច្នេះអង្គការនោះជួយជីកអណ្តូងមួយអោយប្រជាជនដប់គ្រួសារនោះ ។ ដើម្បីអោយទឹកអណ្តូងមានអនាម័យប្រជាជនបានបង្កើតជាក្រុមដើម្បីរក្សាអណ្តូងនោះ ។

**៧៧- ចំនួនក្រុមកសិករប្រើប្រាស់ទឹកស្រោចស្រព** : គឺជាក្រុមដែលបង្កើតឡើងដោយប្រជាជន ក្នុងការប្រើប្រាស់ទឹកស្រោចស្រព។ ឧទាហរណ៍ : ប្រព័ន្ធធារាសាស្ត្រមួយមានប្រភពពីទឹកទន្លេដោយហូរកាត់ភូមិ (ក) ភូមិ(ខ) និងភូមិ(គ) ដូចនេះ ដើម្បីអោយមានប្រភពទឹកគ្រប់គ្រាន់ គាត់បានបង្កើត

ជាក្រុមកសិករដោយមានតំណាងពីភូមិទាំងបី ដើម្បីថែរក្សាម៉ាស៊ីនបូមទឹក និងដើម្បីធ្វើអន្តរាគមន៍នៅពេលដែលមានភាពរាំងស្ងួត ។

ចូរសំគាល់ថា សហគមណ៍ជនបទ គឺជាក្រុមធ្វើសកម្មភាពដែលមានសមាជិកភាគច្រើនជាប្រជាជនក្នុងភូមិ សំរាប់បំរើ ឬ ការពារប្រយោជណ៏អោយអ្នកភូមិ ។

≈≈≈≈

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ១៥២ កធសសរ**

* * *

**រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត នៃនិកាយ " **ប្រេស្ទ្រីន** " នៅខេត្តកំពង់ធំ របស់លោក **គង់ សំអឿន** អាយុ ៥៨ឆ្នាំ . ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១

យោងចំណារឯកភាពរបស់សាលាខេត្តកំពង់ លេខ ៩៣បជ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រិស្ត ឈ្មោះ " **ប្រេស្ទ្រីនបាជ័យ** " មួយ កន្លែងដែលមានទីតាំងស្ថិតនៅក្រុមទី១២ ភូមិបាជ័យ ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

**ប្រការ ២ :** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ម្រេត្រីនធាជ័យ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត " **ម្រេត្រីនធាជ័យ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣ :** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ម្រេត្រីនធាជ័យ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តណាទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តណ៍សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ជា សាវឿន**

~~~

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ១៥៣ ភធសសរ

~~~

## រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ នៃនិកាយ " **បាប់ទីស្ទ** " នៅរាជធានីភ្នំពេញ របស់លោក **អ៊ុក ម៉ិនធឿន** អាយុ ៣៥ឆ្នាំ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០០
- យោងចំណារឯកភាពរបស់សាលាក្រុងភ្នំពេញ លេខ ១២១ លស ។ស ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំ នៃសាសនាគ្រិស្ត ឈ្មោះ " **បាប់ទីស្ទគ្រួសារព្រះ** " មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៤៩ ក្រុមទី២ ភូមិទួលគោក សង្កាត់ទួលសង្កែ ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំ " **បាប់ទីស្ទគ្រួសារព្រះ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វ ផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការ " **បាប់ទីស្ទគ្រួសារព្រះ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តណ៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តណ៍សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធ-ភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ជា សាវឿន**

≈≈≈

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ១៥៤ កធសសរ**

* * *

**រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ នៃនិកាយ " **បាប់ទីស្ទ** " នៅរាជធានី ភ្នំពេញ របស់លោក **ម៉ុម មុរុណា** អាយុ ៣០ឆ្នាំ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០០
- យោងចំណារឯកភាពរបស់សាលាសាលាក្រុងភ្នំពេញ លេខ ១២១ លស.។ស ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រិស្ត ឈ្មោះ " **ក្រុមជំនុំគ្រីស្ទបរិស័ទបាប់ទីស្ទភ្នំពេញទី១** " មួយកន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ០៧ ផ្លូវលេខ ៤៨៨ ក្រុមទី២៤ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ ខែ_____ ឆ្នាំ______

**ប្រការ ២ :** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ក្រុមជំនុំគ្រិស្តបរិស័ទឆាប់ទីស្មន្តីពេញទី១** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣ :** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ក្រុមជំនុំគ្រិស្តបរិស័ទឆាប់ទីស្មន្តីពេញទី១** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សង្រ្គាជាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តណ៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តណ៍សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
**ជា សាវឿន**

* * *
* *